# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2019, 14:38
CMS/CFO: Sann Rada

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

**ភាគីដាក់ឯកសារ:** ក្រុមមេធាវីការពារក្តីលោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៩

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ត.ក** **សាធារណៈ/Public**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ**

**ហត្ថលេខា:**

---

## សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខនៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា

---

| **ដាក់ដោយ៖** | **ផ្ញើជូន៖** | |
|---|---|---|
| **ក្រុមមេធាវីការពារក្តី នួន ជា** | **អង្គជំនុំជម្រះតុលាការកំពូល:** | **សហព្រះរាជអាជ្ញា** |
| សុន អរុណ | ចៅក្រម គង់ ស្រីម, ប្រធាន | ជា លាង |
| លីវ សុវណ្ណា | ចៅក្រម Chandra Nihal JAYASINGHE | Brenda J. HOLLIS (បម្រុង) |
| Doreen CHEN<br>Xiaoyang NIE<br>Marina HAKKOU | ចៅក្រម សោម សិរិវឌ្ឍ | **សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី** |

ឌី សុជាតា

Gaëlle BUCHET
Stephanie ERIAN
Khady BÂ

មេធាវីក្រុម Florence Ndepele Mwachande MUMBA

មេធាវីក្រុម ម៉ុង មុន្នីចរិយា

មេធាវីក្រុម Phillip RAPOZA

មេធាវីក្រុម យ៉ា ណារិន

ពេជ អង្គ

**ក្រុមមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

## ផ្នែកទី 1. សេចក្តីផ្តើម

1. ដោយអនុលោមតាមវិធាន២ ៩២ និង ១០៤ស្ទួន នៃវិធានផ្ទៃក្នុង និងដោយហេតុថា មរណភាពរបស់ នួន ជា កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩[1] សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") ដាក់សំណើបន្ទាន់នេះ ស្នើសុំទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០២ ចំពោះមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ("សំណើ")។ ចំពោះសំអាងហេតុដែលរៀបរាប់នៅក្នុងសំណើនេះ មេធាវីការពារក្តី សូមស្នើថា :

(ក) ស្នើសុំអង្គជំនុំជម្រះ

(i) ទទួលយកសំណើរនេះថាដាក់បញ្ចូលបានត្រឹមត្រូវនិងបានការ ដោយហេតុថា ក្រុមមេធាវីការពារក្តីបានទទួលលិខិតអនុញ្ញាតិជាលាយលក្ខអក្សរពីលោក នួន ជា ដើម្បីធ្វើបន្តនីតិវិធីក្នុងនាមរូបគាត់ ឬ បើមិនដូច្នេះទេ សូមអោយ៖

(ii) សម្រេចចិត្តលើប្រធានបទនៃសំណើរនេះដោយឆន្ទានុសិទ្ធិ ផ្អែកលើការគិតពីផលប្រយោជន៍យុត្តិធម៌[2]។

(ខ) ស្នើសុំអង្គជំនុំជម្រះសម្រេចថា៖

(i) បញ្ចប់នីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងលោក នួន ជា ដែលនាំអោយសាលក្រមក្នុងសំណុំរឿង០០២/០២ ចំពោះលោក នួន ជា ត្រូវអស់អានុភាពអនុវត្តទាំងស្រុង ដោយហេតុថា លោក នួន ជា នៅតែទទួលបាននូវសិទ្ធិសន្មតជាមុនថាគ្មានទោសក្រោយពេលបានប្តឹងសាទុក្ខ ឬ

(ii) ឬបើមិនដូច្នេះទេ អនុញ្ញាតឲ្យនីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងលោក នួន ជា បន្តដំណើរការទៅមុខដើម្បីបម្រើប្រយោជន៍យុត្តិធម៌ ដោយធានាឲ្យលោក នួន ជា ទទួលបានការការពារដោយក្រុមមេធាវីការពារក្តីតាមឆន្ទះរបស់គាត់ ក្រោយពីរូបលោកទទួលមរណភាព។

---

[1] មើល F46/1.1 លិខិតមរណភាពរបស់ នួន ជា ERN 01623650(KH), 01623651 (EN)

[2] បញ្ហានេះត្រូវបានដោះស្រាយនៅក្នុងតុលាការអន្តរជាតិផ្សេងទៀត។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ច្រានចោលសំណើរបស់មេធាវីការពារក្តីបានដាក់ក្នុងនាមកូនប្រុសរបស់ Delic ក្នុងមូលហេតុកន្លះនូវជំហរ ប៉ុន្តែអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដូចគ្នានៅថ្ងៃដដែលលើបញ្ហាពិចារណាដោយឆន្ទានុសិទ្ធិរបស់ខ្លួន : មើល ខាងក្រោម ព្រះរាជអាជ្ញា ទល់នឹង Delic, IT 04-08-A "**សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង** *Delić*" ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១០ ("សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង Delić ")។

(គ) ប្រសិនបើ មានភាពចាំបាច់ សូមអោយចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ស្នើសុំ វិសោធនកម្មលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក តាមរយៈការប្រជុំពេញអង្គរបស់ អ.វ.ត.ក ដើម្បីបង្ហាញអោយឃើញច្បាស់ពីវិធានដែលអាចអនុវត្តបាន ពាក់ព័ន្ធនឹងប្រធានបទដែលត្រូវបានលើកឡើងក្នុងសំណើនេះ។

(ឃ) ស្នើសុំអង្គជំនុំជម្រះ៖

(i) ផ្តល់នូវសេចក្តីសម្រេចនេះ ឬសេចក្តីសម្រេចច្រានចោលក្នុងកម្រិតអប្បបរមាដោយមានសេចក្តីសម្រេចដ៏សមហេតុផលមួយ ដើម្បីឱ្យមានការអនុវត្តឆាប់រហ័សតាមដែលអាចធ្វើទៅបាន - ដោយឈរលើមូលដ្ឋាននៃភាពបន្ទាន់ និង

(ii) ចេញដីកាបង្គាប់បណ្តោះអាសន្ន មុនពេលផ្តល់នូវសេចក្តីសម្រេចណាមួយ ដោយផ្តល់នូវការរក្សាទុកក្រុមមេធាវីការពារក្តី រហូតដល់ពេលណាមួយសមស្រប ដែលកំណត់ដោយអង្គជំនុំជម្រះ បន្ទាប់ពីមានការចេញនូវសេចក្តីសម្រេចនេះ។

2. មេធាវីការពារក្តី បានទទួលការអនុញ្ញាតដោយផ្ទាល់មាត់ពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ដើម្បីដាក់សំណើនេះតែមួយភាសា ជាភាសាអង់គ្លេស ដោយដាក់ភាសាខ្មែរនៅតាមក្រោយ។

## ផ្នែកទី២ សាវតា

## I. <u>ការទទួលមរណភាពរបស់ នួន ជា</u>

3. ក្រោមពេលបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដើម្បីព្យាបាលកាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាពនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៩ មេលាម៉ោង ៦ ល្ងាច[3]។

[3] មើល F46/1.1 លិខិតមរណភាពរបស់ នួន ជា ERN 01623650(KH), 01623651 (EN)

## II. អធិក្ខមាននៃយុត្តិសាស្ត្រ អ.វ.ត.ក ស្តីពីផលប៉ះពាល់នៃមរណភាពរបស់ដើមបណ្ដឹងសាទុក្ខ

4 អង្គជំនុំជម្រះនេះ និងអង្គជំនុំជម្រះផ្សេងទៀតនៅ **អ.វ.ត.ក** បានទទួលឱកាសរួចហើយក្នុងការពិចារណាពីផលប៉ះពាល់នៃមរណភាពរបស់ជនជាប់ចោទ តាមរយៈអលទ្ធភាពនិងការទទួលមរណភាពរបស់ នួន ជា នៃសំណុំរឿង ០០២ សហជនជាប់ចោទ អៀង ធីរិទ្ធ និង អៀង សារី។ ប៉ុន្តែ ការពិភាក្សានេះ ត្រូវបានកំណត់កាលៈទេសៈអំពីការទទួលមរណភាព*នៅក្នុងអំឡុងពេលជំនុំជម្រះ*។ ពុំទាន់មានយុត្តិសាស្ត្រ **អ.វ.ត.ក** ត្រូវបានពិចារណាលើការទទួលមរណភាពនៃដើមបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ឬការពិនិត្យលម្អិតផ្តោតលើបញ្ហាដែលលើកឡើងនៅក្នុងសំណើនេះ ឧទាហរណ៍ ផលប៉ះពាល់នៃការទទួលមរណភាពស្តីពីការសន្មតជាមុនថាគ្មានទោសនៃដើមបណ្តឹងសាទុក្ខដែលបានទទួលមរណភាព។

## III. ការផ្តល់សិទ្ធិរបស់ នួន ជា ដើម្បីបន្តនីតិវិធី ក្នុងនាមរូបគាត់បន្ទាប់ពីមរណភាពរបស់ខ្លួន

5. អ្វីដែលវិធានផ្ទៃក្នុង អ.វ.ត.ក ធ្វើការបញ្ជាក់ច្បាស់ គឺនៅក្នុងវិធាន១១២(១) គឺថា ក្រោយពេលទណ្ឌិតទទួលមរណភាព "សហព័ទ្ធ កូន ឪពុកម្តាយ ឬបុគ្គលដទៃទៀត ដែលមានជីវិតរស់រាននៅពេលមរណភាពរបស់ទណ្ឌិត ហើយបានទទួលនូវបណ្តាំជាលាយលក្ខអក្សរពីទណ្ឌិត ឲ្យធ្វើបណ្ដឹងសើរើ [. . .] អាចធ្វើបណ្តឹងសើរើ ចំពោះសាលក្រមស្ថាពរ" នៅក្នុងកាលៈទេសៈជាក់ស្តែង។ នេះទាក់ទងនឹងការរកឃើញ ភស្តុតាងថ្មី មានកំហុស មានការក្លែងបន្លំ ឬខុសពីការពិត តាមរយៈភស្តុតាងដែលត្រូវជំនុំជម្រះ និងយកមកធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោស ឬក៏ការប្រព្រឹត្តកំហុសធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬបំពានលើតួនាទី ដោយចៅក្រមម្នាក់ដែលបានចូលរួមនៅក្នុងនីតិវិធីស៊ើបអង្កេត ឬផ្តន្ទាទោស។

6. ទាក់ទងនឹងវិធានផ្ទៃក្នុង ១១២(១) និង កាលៈទេសៈ ព្រមទាំងបញ្ហាពិភាក្សានៅក្នុងសំណើនេះ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ នួន ជា បានផ្តល់រួចរាល់នូវលិខិតប្រគល់សិទ្ធិជាលាយលក្ខអក្សរសម្រាប់មេធាវីការពារក្តី និងសមាជិកគ្រួសារជាក់លាក់ក្នុងការតំណាងក្នុងនាមរូបគាត់ បើទោះបីជាគាត់ទទួលមរណភាពក៏ដោយ។ មេធាវីការពារក្តី បានដាក់លិខិតប្រគល់

សិទ្ធិនេះ ជូនអង្គជំនុំជម្រះនៅក្នុងមូលដ្ឋានសម្រាត់បំផុត នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩[4]។ ឯកសារជាសាធារណៈ (កោសលុប) ត្រូវបានភ្ជាប់ជូននៅក្នុងសំណើនេះ[5]។

## ផ្នែកទី៣ ច្បាប់អនុវត្ត

7. មាត្រា ១២ (១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចោទប្រកាន់នៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មបានប្រព្រឹត្តក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង អ.វ.ត.ក”) ចែងថា:

> នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ចំពោះការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នា រវាងបទបញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ។

8. ដូចគ្នា នៅក្នុងមាត្រា ៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា:

> ក្នុងករណីនីតិវិធីដែលមានស្រាប់ ពុំអាចដោះស្រាយចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ចំពោះការបកស្រាយ ឬការអនុវត្តបទបញ្ញត្តិណា ដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នា រវាងបទបញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ។

9. ត្រឹមតែការសន្មតជាមុនថាគ្មានទោស ត្រូវជាប់ពាក់ព័ន្ធ មាត្រា៣៥ថ្មី នៃច្បាប់ អ.វ.ត.ក លើកឡើងថា “ជនជាប់ចោទ ត្រូវទទួលបានការសន្មត់ជាមុនថាគ្មានទោស រហូតដល់ពេលដែលតុលាការចេញសាលក្រម**ស្ថាពរ**” (បន្ថែមផ្ទេដិត)។

---

[4] F46 លិខិតរបស់ នួន ជា ផ្តល់សិទ្ធិឲ្យបុគ្គលមួយចំនួនក្នុងការបន្តនីតិវិធីក្នុងនាមរូបគាត់ ក្នុងករណីគាត់ទទួលមរណភាពនៅពេលណាមួយមុនបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ” ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩

[5] លិខិតរបស់ នួន ជា ផ្តល់សិទ្ធិឲ្យបុគ្គលមួយចំនួនក្នុងការបន្តនីតិវិធីក្នុងនាមរូបគាត់ ក្នុងករណីគាត់ទទួលមរណភាពនៅពេលណាមួយមុនបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ (សាធារណៈ (កោសលប់) ឯកសារយោងទី១)។

10. ទាក់ទងនឹងវិធានដែលទើបតែបានលើកឡើង គឺគួរតែត្រូវបានគត់សម្គាល់ដែរថា មាត្រា៣៧ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា "គោលការណ៍ច្បាប់នៃ៣៣,៣៤ និង៣៥ ត្រូវអវនុវត្តដូចគ្នា"នៅក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

11. ដោយហេតុថា ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ច្បាប់ អ.វ.ត.ក មាត្រា ៣៦ ថ្មី បញ្ញត្តិថា អង្គជំនុំជម្រះតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខ ដាក់ដោយគ្រប់ភាគីទាំងអស់ ហើយអង្គជំនុំជម្រះតុលាការកំពូល ពិនិត្យ សម្រេច**ជាចុងក្រោយ**ទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ ដោយយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះសាលាដំបូងវិញទេ(បន្ថែមផ្នែកដិត)។

12. ជាចុងក្រោយ វិធានផ្ទៃក្នុង ២១(១) ចែងថា "ច្បាប់អនុវត្តនៅ អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវពីសច្ចភាពតាមផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" (បន្ថែមផ្នែកដិត)។

## ផ្នែកទី៤ អំណះអំណាង

### I. កិច្ចព្រមព្រៀង អ.វ.ត.ក កំណត់វិធានច្បាស់លាស់អំពីការបកស្រាយលើច្បាប់នីតិវិធីរបស់ អ.វ.ត.ក

13. កិច្ចព្រមព្រៀង អ.វ.ត.ក បានបង្កើតឡើងថា អ.វ.ត.ក គឺជាអង្គជំនុំជម្រះវិសាមញ្ញ "ដែលរួមបញ្ចូលរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់"[6] ហើយនីតិវិធី អ.វ.ត.ក "ត្រូវអនុលោមតាមច្បាប់កម្ពុជា" ដើម្បីកំណត់ថា ច្បាប់កម្ពុជា មានភាពស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋានអន្តរជាតិ[7]។

14. ដើម្បីអនុវត្តកិច្ចព្រមព្រៀងខាងលើ កិច្ចប្រជុំពេញអង្គ អ.វ.ត.ក បានអនុម័តនូវវិធានផ្ទៃក្នុង "ដើម្បីរួមបញ្ចូលការអនុវត្តកិច្ចដំណើរការនីតិវិធីកម្ពុជានៅចំពោះមុខ អ.វ.ត.ក" និងធានាពីភាពស៊ីសង្វាក់គ្នានៃវិធាន ជាមួយនឹងបទដ្ឋានអន្តរជាតិ[8]។

15. ហេតុដូច្នេះ ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងយ៉ាងត្រឹមត្រូវ:

---

[6] កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា

[7] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១)

[8] វិធានផ្ទៃក្នុង បុព្វកថា

ដូច្នេះ វិធានផ្ទៃក្នុងមានទម្រង់របបនៃការបង្កើតនូវច្បាប់នីតិវិធីដោយខ្លួនឯងផ្ទាល់ ដោយមូលហេតុនៃកាលៈទេសៈពិសេសរបស់វាដែលខុសប្លែកពីករណីដទៃ ត្រូវបង្កើតឡើង និងយល់ស្របតាមដោយកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. វិធានទាំងនោះពុំអាចប្រឆាំងគ្នានឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានទេ ប៉ុន្តែខុសប្លែកគួរអោយកត់សម្គាល់បើប្រៀបធៀបនឹងប្រតិបត្តិការទូទៅនៃតុលាការព្រហ្មទណ្ឌនៃប្រទេសកម្ពុជា និងដើម្បីធានាអោយបាននូវប្រព័ន្ធជាក់លាក់ត្រឹមត្រូវមួយ[9]។

16. និយាយម្យ៉ាងទៀត វិធានផ្ទៃក្នុង គឺជាច្បាប់ពិសេស ប្រៀបទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ វិធានផ្ទៃក្នុង គឺជាឯកសារមូលដ្ឋាន នៃឯកសារយោងសម្រាប់នីតិវិធី អ.វ.ត.ក។ ក្នុងនាមជាច្បាប់ទូទៅ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺជាឯកសារយោងបន្ទាប់ នៅពេលដែលវិធានផ្ទៃក្នុងពុំបានចែងស្តីពីបញ្ហាពិសេសណាមួយ។

17. នៅពេលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេប្រើប្រាស់ជាឯកសារយោងច្រើនការបកស្រាយពីជំហររបស់ខ្លួន ត្រូវគេទាញអោយចូលក្នុងបរិបទទាំងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជា ឯកសារច្បាប់ អ.វ.ត.ក ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ និងពុំគួរចាត់ជាឯកសារពុំមានប្រសិទ្ធភាពណាមួយឡើយ (យោងតាមគោលការណ៍នៃប្រសិទ្ធិភាព)។ លើសពីនេះ ភាពស៊ីសង្វាក់គ្នានៃច្បាប់ទាំងឡាយទាក់ទងនឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងបទដ្ឋានអន្តរជាតិ ត្រូវតែធ្វើការពិនិត្យនៅចំពោះមុខអង្គជំនុំជម្រះនានានៅអ.វ.ត.ក ថាអាចអនុវត្តបាន[10]។ ក្នុងករណីតែមួយគត់ ប្រសិនបើច្បាប់ដែលបានលើកឡើង មានភាពផ្ទុយគ្នាពីបទដ្ឋានអន្តរជាតិ នឹងមានមូលដ្ឋានសស្របច្បាប់

[9] D55/1/8 “សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីបង្គាប់ច្រានចោលសំណើសុំធ្វើមោឃភាព” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ (សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីបង្គាប់ច្រានចោលសំណើសុំធ្វើមោឃភាព) កថាខណ្ឌ១៤ (បន្ថែមផ្នែកដិត)។ អង្គជំនុំជម្រះនេះ ក៏បានអនុម័តស្រដៀងគ្នាក្នុងការឈានទៅរកទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីកម្ពុជា។ មើល ឧទាហរណ៍ **E50/3/1/4** “សេចក្តីសម្រេចភ្លាមៗលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់” ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ២៨។

[10] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១), ច្បាប់ អ.វ.ត.ក មាត្រា៣៣ថ្មី និងវិធានផ្ទៃក្នុង បុព្វកថា។

សម្រាប់អង្គជំនុំជម្រះនានានៃអ.វ.ត.ក ដើម្បីងាកចេញពីបទដ្ឋានអន្តរជាតិទាំងនោះ ហើយបង្កើតឲ្យមានការផ្លាស់ប្តូរថ្មីនៅក្នុងការសំអាងលើបទដ្ឋានអន្តរជាតិ[11]។

18. នៅក្នុងស្ថានភាពដែលទាំងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពុំបានកំណត់ពីច្បាប់ពាក់ព័ន្ធ ទាក់ទងនឹងបញ្ហាលើកឡើង អង្គជំនុំជម្រះ អ.វ.ត.ក នឹងត្រូវតែផ្អែកទៅលើច្បាប់នីតិវិធីនៅក្នុងលំដាប់អន្តរជាតិ ដើម្បីដោះស្រាយ[12]។

19. នៅផ្នែកខាងមុខ នៅក្នុងសំណើនេះ មេធាវីការពារ នឹងពិភាក្សាដំបូងគេ ថាតើវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានចែងច្បាប់ទាក់ទងនឹងការគ្រប់គ្រងលើស្ថានភាពនៃមរណភាពរបស់ដើមបណ្តឹងសាទុក្ខ (ផ្នែកទីII) ហើយបន្ទាប់មកវាយតម្លៃថាតើច្បាប់ពាក់ព័ន្ធដែលមានស្រាប់គឺស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ (ផ្នែកទីIII) និងចុងក្រោយ ពិភាក្សាថាតើអវត្តមាននៃច្បាប់ជាក់លាក់អាចធានានូវការបង្កើតឲ្យមានការផ្លាស់ប្តូរថ្មីដោយអង្គជំនុំជម្រះ (ផ្នែកទីIV)។

II. វិធានផ្ទៃក្នុង និងច្បាប់កម្ពុជា បង្ហាញថា មរណភាពនៃដើមបណ្តឹងសាទុក្ខ នាំឲ្យបញ្ចប់កិច្ចដំណើការនីតិវិធី ហើយសាលក្រមត្រូវចាត់ទុកថាពុំមានអានុភាពអនុវត្ត

20. វិធានផ្ទៃក្នុងពុំបានចែងអំពីផលប៉ះពាល់នៃមរណភាពដើមបណ្តឹងសាទុក្ខក្នុងអំឡុងពេលកិច្ចដំណើការនីតិវិធីនៅចំពោះមុខអ.វ.ត.កឡើយ។ ឧទាហរណ៍ មាត្រា ២៣ស្ទួន(៦) គ្រាន់តែបានលើកឡើងចំពោះការបញ្ចប់ដំណើរការបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទ (ឧទាហរណ៍ជនដែលប្រឈមមុខនឹងការជំនុំជម្រះ) ក្នុងករណីជននោះទទួលមរណភាព។

21. យោងតាមការបកស្រាយច្បាប់ កំណត់នៅក្នុងផ្នែកទីI ដែលក្នុងករណីមានចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង ការដោះស្រាយ ដំបូងត្រូវមើលនៅក្នុងច្បាប់កម្ពុជា។ មាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

[11] សំណុំរឿង ០០១, F36 "សាលដីកា" ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៤១៤។ មេធាវីការពារក្តី កត់សម្គាល់ថា ដូចដែលអង្គជំនុំជម្រះបានលើកឡើងកន្លងមក "ការង្កើតថ្មី" គឺត្រូវបានបញ្ចប់នូវ "ការបកស្រាយ", មើល E138/1/10/1/5/7 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធិ ដោយឥតលក្ខខណ្ឌ" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ("សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងការដោះលែង អៀង ធីរិទ្ធិ") កថាខណ្ឌ ៣៣ មើលផងដែរ ផ្នែក៤ ចំណុច IV-ង។

[12] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១), ច្បាប់ អ.វ.ត.ក មាត្រា៣៣ថ្មី និងវិធានផ្ទៃក្នុង បុព្វកថា។

នៃព្រះរាជាណាចក្រកម្ពុជា ចែងថា “មរណភាពនៃជនល្មើស” គឺជាមូលហេតុ “សម្រាប់ការរំលត់បណ្តឹងអាជ្ញា”។ ប៉ុន្តែ បញ្ហានៃការបញ្ចប់នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ គឺពុំទាន់បានកំណត់នៅក្រោមច្បាប់កម្ពុជានៅឡើយ”។ ជាពិសេស ក្នុងករណីនេះ គឺពុំមានភាពច្បាស់លាស់ថាតើសាលក្រមអង្គជំនុំជម្រះសាលាដំបូង ត្រូវចាត់ទុកថាស្ថាពរ នៅក្នុងកាលៈទេសៈដែលដើមបណ្តឹងសាទុក្ខទទួលមរណភាពនៅមុនពេលចេញសាលដីកា។

22. ដូចដែលបានលើកឡើងខាងលើនៅក្នុងផ្នែកទីI ការអនុវត្តច្បាប់កម្ពុជា ដើម្បីបន្តកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវតែបកស្រាយនៅក្នុងបរិបទនៃឯកសារច្បាប់ អ.វ.ត.ក។ មាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា “ជនជាប់ចោទត្រូវសន្មតជាមុនថាគ្មានទោស ដ៏រាបណាពុំទាន់មានសាលក្រម**ស្ថាពរ**” (បន្ថែមផ្នែកដិត)។ ផ្អែកលើមាត្រា ៣៧ថ្មី ប្រការនេះ ត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីបណ្តឹងសាទុក្ខ។ លើសពីនេះ មាត្រា ៣៦ថ្មី និងវិធានផ្ទៃក្នុង ១១១(៦) បញ្ជាក់ថា ក្នុងករណីបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូល “ត្រូវចេញសេចក្តីសម្រេច**ជាចុងក្រោយ**ទាំងផ្នែកអង្គច្បាប់ និងអង្គហេតុ” ហើយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជា**ស្ថាពរ** “ក្នុងករណីដែលបណ្តឹងសាទុក្ខត្រូវបាន**បដិសេធ**” (បន្ថែមផ្នែកដិត)។ ក្នុងន័យនេះ ការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីពុំមែនជាការច្រានចោលបណ្តឹងសាទុក្ខឡើយ ក្នុងករណីដែលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខត្រូវបិទបញ្ចប់ដោយសារមូលហេតុមរណភាពដើមបណ្តឹងសាទុក្ខ ដូច្នេះ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែអស់អានុភាពអនុវត្ត ហើយត្រូវតែគោរពតាមគោលការណ៍សន្មតជាមុនថាគ្មានទោស។

23. នៅផ្នែកបន្ទាប់ ច្បាប់នីតិវិធីដែលមានស្រាប់នៅ អ.វ.ត.ក បង្គាប់ថា ដោយសារមូលហេតុនៃមរណភាពដើមបណ្តឹងសាទុក្ខ **កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី ត្រូវបិទបញ្ចប់ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវអស់អានុភាពអនុវត្ត និងត្រូវរក្សាការសន្មតជាមុនថាគ្មានទោស**។ សេចក្តីសន្និដ្ឋាននេះ ក៏នឹងត្រូវពិភាក្សានៅខាងក្រោម ដែលជាភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋាន និងច្បាប់ បង្កើតនៅក្នុងលំដាប់អន្តរជាតិ។

## III. ការបញ្ចប់នីតិវិធីដែលមោឃៈសាលក្រមគឺសមស្របជាមួយនឹងបទដ្ឋានអន្តរជាតិ

### ក. វិធាននីតិវិធីដែលអនុវត្តនៅ អ.វ.ត.ក ត្រូវសមស្របតាមបទដ្ឋានអន្តរជាតិ

២៤. ដូចបានបញ្ជាក់ខាងលើបញ្ញត្តិពាក់ព័ន្ធដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនិងវិធាននៃផ្ទៃក្នុងត្រូវតែស្របជាមួយនឹងបទដ្ឋានអន្តរជាតិដើម្បីអនុវត្តនៅក្នុងអ.វ.ត.ក។ "បទដ្ឋានអន្តរជាតិ" នៅក្នុងបរិបទនេះសំដៅលើ "បទដ្ឋានអន្តរជាតិនៃយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងកាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនិងឧបករណ៍ច្បាប់ផ្សេងទៀត"[13]និងគួរឲ្យកត់សម្គាល់នោះគឺ "បទដ្ឋានអន្តរជាតិនៃយុត្តិធម៌និងដំណើរការសមស្របនៃច្បាប់ ដូចបានកំនត់នៅក្នុងមាត្រា ១៤ និង ១៥ នៃកាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ១៩៦៦ ("ICCPR")។[14] បទដ្ឋានពីរដែលរំលេចឡើងនៅក្នុងមាត្រា ១៤ នៃ ICCPR គឺជាគោលការណ៍មូលដ្ឋាននៃសិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍និងសិទ្ធិមូលដ្ឋានក្នុងការទទួលបានការពិនិត្យដោយតុលាការជាន់ខ្ពស់ចំពោះការកាត់ទោសនិងដាក់ទោសទៅលើបុគ្គលមួយ។[15]

២៥. បទដ្ឋានអន្តរជាតិកំណត់អំពី**គោលការណ៍**ណែនាំជាជាង**វិធាន**នៃនីតិវិធីជាក់ច្បាស់។ ដើម្បីកំណត់ វិធានជាក់ច្បាស់ដែលអាចអនុវត្តតាមស្របតាមបទដ្ឋានអន្តរជាតិ អង្គជំនុំជម្រះ អ.វ.ត.ក ត្រូវយោងទៅលើការអនុវត្តក្នុងស្រុកនិងវិធាននៃតុលាការអន្តរជាតិផ្សេងទៀតជាលំនាំ។[16]

២៦. គួរឲ្យកត់សម្គាល់ផងដែរនៅក្នុងបញ្ហានេះ នីតិវិធីព្រហ្មទណ្ឌមិនមែនជាប្រធានបទនៃច្បាប់អន្តរជាតិនោះទេដោយនីតិវិធីនេះជាប្រធានបទដែលគ្រប់គ្រងដោយច្បាប់ជាតិ។ គ្មានសន្ធិសញ្ញាអន្តរជាតិណាដែលអនុវត្តចំពោះប្រធានបទនេះទេ។ ហើយក៏គ្មានច្បាប់ទំនៀមទម្លាប់អន្តរជាតិណាដែលបានបង្កើតឡើងសម្រាប់បញ្ហានេះដែរ។ សម្រាប់នីតិវិធីព្រហ្មទណ្ឌ តុលាការជាតិបានប្រើច្បាប់ជាតិ

[13]ឯកសាររបស់ អ.ស.ប លេខ A/53/850, S/1999/231 ១៦ មីនា ១៩៩៩ ឧបសម្ព័ន្ធ, "របាយការណ៍នៃក្រុមជំនាញការសម្រាប់កម្ពុជាដើម្បីការបង្កើតស្របតាមសេចក្តីសម្រេចរបស់សន្ធបាទទូទៅ 52/135", ១៨ កុម្ភៈ ១៩៩៩ (**ឧបសម្ព័ន្ធ ២**) កថាខណ្ឌ ១២៩។

[14]ច្បាប់ អ.វ.ត.ក មាត្រា ៣៣*ថ្មី*។

[15]ICCPR មាត្រា ១៤(២) និង (៥)។

[16]ជាឧទាហរណ៍ នៅពេលដែលសម្រេចអំពីវិធានដែលអនុវត្តចំពោះការដោះលែងដោយគ្មានលក្ខខណ្ឌ អង្គជំនុំជម្រះ បានធ្វើការស្ទង់មតិដោយទូលាយមួយ ចំពោះការអនុវត្តនៅតាមបណ្តាយុត្តាធិការក្នុងស្រុកមួយចំនួននិងវិធានឬការ អនុវត្ត នៅតាមបណ្តាតុលាការអន្តរជាតិ(ឬតុលាការដែលកំពុងក្លាយជាតុលាការអន្តរជាតិ) : *សូមមើល* E138/1/10/1/5/7សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការដោះលែង អៀង ធីរិទ្ធ។

ដែលមិនត្រូវបានចាត់ទុកថាជាការអនុវត្តរបស់រដ្ឋមួយឬផ្ទុះបញ្ចាំងអំពី *ទ្រឹះស្តីយុត្តាធិការ(opinion juris)* នោះឡើយ។

២៧. ដូចបានសម្រេចដោយត្រឹមត្រូវដោយតុលាការយុត្តិធម៌អន្តរជាតិ ("ICJ") នៅលើសំណុំរឿង *Barcelona Traction* ចំពោះបញ្ហាផ្លូវច្បាប់ដែលកើតឡើងនៅក្នុងយន្តហោះអន្តរជាតិ ហើយច្បាប់អន្តរជាតិមិនបានបង្កើតវិធានផ្ទាល់នោះទេ ដោយករណីនេះត្រូវយោងទៅច្បាប់ជាតិ ឧ.ហ វិធានដែលតែងតែទទួលស្គាល់ជាទូទៅដោយប្រព័ន្ធច្បាប់ជាតិ។[17]

២៨. ដូចគ្នានេះដែរ ក្នុងសំណុំរឿង Furundžija អង្គជំនុំជម្រះ ICTY បានស្វែងរកក្នុងច្បាប់ជាតិនូវគោលការណ៍ណែនាំ នាពេលដែលច្បាប់អន្តរជាតិមិនបានផ្តល់និយមន័យត្រឹមត្រូវចំពោះបទល្មើសរំលោភ ដែលអាចបំពេញលក្ខខណ្ឌនៃភាពជាក់ច្បាស់សម្រាប់គោលការណ៍ច្បាប់ព្រហ្មទណ្ឌ។[18] នៅក្នុងបរិបទនេះ អង្គជំនុំជម្រះ ICTY បានសម្រេចថា "[នៅ]ពេលណាដែលវិធានព្រហ្មទណ្ឌអន្តរជាតិមិនអាចឲ្យនិយមន័យលើសញ្ញាណនៃច្បាប់ព្រហ្មទណ្ឌ ការពឹងផ្អែកទៅលើច្បាប់ជាតិគឺគ្រប់គ្រាន់"។[19]ហេតុផលដូចគ្នានេះអនុវត្តចំពោះវិធាននិងសញ្ញាណជាក់លាក់នៃនីតិវិធីព្រហ្មទណ្ឌ។

**ខ. ទោះបីជាច្បាប់ជាតិនៃរដ្ឋនីមួយៗមិនដូចគ្នា ខ្លឹមសារនៃវិធានរបស់ អ.វ.ត.ក គឺស្របគ្នានៅនឹងច្បាប់ជាតិនៃរដ្ឋដែលមានប្រភពមកពីប្រព័ន្ធច្បាប់ស្រដៀងគ្នា**

២៩. នៅក្នុងបរិបទនេះ អង្គភាពគាំពារក្តីបានធ្វើការស្ទង់មតិអំពីវិធាននីតិវិធីនិងការអនុវត្តនៅក្នុងយុត្តាធិការក្នុងស្រុកមួយចំនួនពាក់ព័ន្ធនឹងផលប៉ះពាល់នៃការស្លាប់របស់ដើមបណ្តឹងសាទុក្ខមុនពេលទទួលបានការប្រកាសសាលដីកានៃបណ្តឹងសាទុក្ខ។ វិភាគទៅលើពេលវេលាដែលមានកំណត់សម្រាប់អង្គភាពគាំពារក្តី ការស្ទង់មតិនេះមិនបានធ្វើឡើងឲ្យបានក្បោះក្បាយ ប៉ុន្តែមានប្រយោជន៍ក្នុងការបង្ហាញយ៉ាងសមស្របមួយនូវប្រព័ន្ធច្បាប់ចម្បងៗនៅទីកន្លែងមួយចំនួនជុំវិញពិភពលោក។ ដូចដែលបានបង្ហាញខាងក្រោមនេះ ការស្ទង់មតិបានបង្ហាញថា ៖

[17]រឿងក្តី*ពាក់ព័ន្ធនឹង Barcelona Traction, ក្រុមហ៊ុនភ្លើងនិងថាមពល, មានកម្រិត (បែលហ្ស៊ិក v. អេស្ប៉ាញ)*, ICJ, "សាលក្រម", ៥ កុម្ភៈ ១៩៧០ (**ឧបសម្ព័ន្ធ ៣**) កថាខណ្ឌ ៣៨ និង ៥០។

[18]*ព្រះរាជអាជ្ញាv. Furundžija*, IT-95-17/1-T, "សាលក្រម" ១០ ធ្នូ ១៩៩៨ ("សាលក្រម *Furundžija*") កថាខណ្ឌ ១១៧។

[19]សាលក្រម *Furundžija*, កថាខណ្ឌ ១៧៨។

(ក) ទីមួយ ជាគោលការណ៍ ការស្លាប់របស់ដើមបណ្តឹងសាទុក្ខនឹងបញ្ចប់នីតិវិធី។ នៅក្នុងយុត្តាធិការខ្លះ ការបញ្ចប់នេះគឺជាជម្រើសតែមួយ។ នៅក្នុងយុត្តាធិការខ្លះ លើសពីការបញ្ចប់ តុលាការមាន ជម្រើសផ្សេងក្នុងការបន្តនីតិវិធីក្រោយមរណភាពរបស់បុគ្គលដើមបណ្តឹងសាទុក្ខនៅក្នុងកាលៈទេសៈពិសេស។

(ខ) ទីពីរ មានយុត្តាធិការដែលទទួលស្គាល់សិទ្ធិសន្មត់ជាមុនថាគ្មានទោស នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ រហូតដល់ការប្រកាសសាលដីកានៃបណ្តឹងសាទុក្ខ ការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខមានប្រសិទ្ធិភាពធ្វើឲ្យសាលក្រមសាលាដំបូងអស់អានុភាពអនុវត្ត។

៣០. ការស្ទង់មតិបានបង្ហាញថា ការបញ្ចប់នីតិវិធីនាពេលណាមួយដែលដើមបណ្តឹងសាទុក្ខបានទទួលមរណភាព គឺជាជម្រើសសាមញ្ញមួយនៅក្នុងគ្រប់យុត្តាធិការដែលបានសិក្សា។ នៅក្នុងយុត្តាធិការខ្លះ ការបញ្ចប់គឺជាជម្រើសតែមួយ ឧ.ហ បារាំង[20] បែលហ្ស៊ិក[21] អាល្លឺម៉ង់[22] បូស្នី[23] អូស្ត្រាលី[24] និងយុត្តាធិការនៃរដ្ឋភាគច្រើននៃសហរដ្ឋអាមេរិក[25]។

---

[20] បារាំង *ក្រមនីតិវិធីព្រហ្មទណ្ឌ*មាត្រា ៦ [ការបកប្រែមិនផ្លូវការ] ៈ "មរណភាពរបស់របស់ជនជាប់ចោទបានបញ្ចប់នីតិវិធីព្រហ្មទណ្ឌប្រឆាំងបុគ្គលនោះ។ ជាងនេះទៅទៀត សេចក្តីសម្រេចសាទុក្ខមួយមិនត្រូវចូលជាស្ថាពរ រាល់ហេតុដែល បញ្ចប់នីតិវិធីព្រហ្មទណ្ឌ ដូចកំណត់ក្នុង ប្រការ ៦ មោឃៈសាលក្រមសាលាដំបូង" (**ឧបសម្ព័ន្ធ ៤**)។ *មើល*ផងដែរ *Cour de Cassation, អង្គជំនុំជម្រះព្រហ្មទណ្ឌ*, បារាំង, No. 88-81.542 (១៧ តុលា ១៩៩៥) (**ឧបសម្ព័ន្ធ ៥**) ។

[21] បែលហ្ស៊ិក *សេចក្តីពន្យល់ក្រមព្រហ្មទណ្ឌ* មាត្រា ២០ [ការបកប្រែមិនផ្លូវការ] ៈ "មរណភាពបញ្ចប់សកម្មភាពបណ្តឹង ព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលទទួលមរណភាព។ នៅពេលដែលដើមបណ្តឹងសាទុក្ខទទួលមរណភាពមុនពេល ចេញលទ្ធផលសាទុក្ខ សាលដីកាសាទុក្ខមិនបង្កើតឲ្យមាន*អាជ្ញាអស់ជំនុំ*(*res judicata*) នោះទេ" (**ឧបសម្ព័ន្ធ ៦**)។ *មើល*ផងដែរ *Cour de Cassation*បែលហ្ស៊ិក P951155N (១៧ តុលា ១៩៩៥) (**ឧបសម្ព័ន្ធ ៧**)។

[22] អាល្លឺម៉ង់ *ក្រមនីតិវិធីព្រហ្មទណ្ឌ (StPO)* មាត្រា ២០៦(ក) [ការបកប្រែមិនផ្លូវការ] ៈ "មរណភាពគឺជារបាំងនីតិវិធីមួយ ក្នុងនីតិវិធីព្រហ្មទណ្ឌនិងសេចក្តីសម្រេចផ្លូវការមួយសម្រាប់បិទនីតិវិធីដែលត្រូវចេញ" (**ឧបសម្ព័ន្ធ ៨**)។ *មើល*ផងដែរ *សេចក្តីសម្រេចលើការបញ្ចប់នីតិវិធីសាទុក្ខ ស្របតាមប្រការ ២០៦(a) StPOក្រោយមរណភាពរបស់ John Damanjuk*អាល្លឺម៉ង់ តុលាការតំបន់ម៉ូនិច, LG Munchen II, 1 Ks 115 Js 12496/08 (០៥ មេសា ២០១២) (**ឧបសម្ព័ន្ធ ៩**)។

[23] បូស្នីនិង Herzegovina *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ២០៥ [ការបកប្រែមិនផ្លូវការ]:នីតិវិធីត្រូវបញ្ឈប់ នាពេលដែល ជនជាប់ចោទទទួលមរណភាព (**ឧបសម្ព័ន្ធ ១០**)។

[24] នៅ អូស្ត្រាលី, នីតិវិធីព្រហ្មទណ្ឌត្រូវបានបញ្ចប់នាពេលដែលចុងចោទបានទទួលមរណភាព ដែលមានន័យផងដែរ ថា សិទ្ធិប្តឹងសាទុក្ខត្រូវបានបញ្ចប់ដោយមរណភាពរបស់ពិរុទ្ធជន។ *មើលឯកសារយោងដោយព្រះរាជអាជ្ញារបស់រដ្ឋNew South Wales ក្រោមs. 77(1)(b) នៃច្បាប់ព្រហ្មទណ្ឌ (បណ្តឹងសាទុក្ខនិងការពិនិត្យ) ឆ្នាំ ២០០១ តបទៅនឹងការកាត់ទោសFederick Lincoln*

៣១. នៅក្នុងយុត្តាធិការដទៃនៃការស្ទង់មតិ តុលាការមានជម្រើសផ្សេងក្នុងការបន្តនីតិវិធីក្រោយពេលដែល ដើមបណ្តឹងសាទុក្ខបានទទួលមរណភាពនៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ដូចជា ចក្រភព អង់គ្លេស[26] សិង្ហបុរី[27] បណ្តារដ្ឋខ្លះនៅសហរដ្ឋអាមេរិក[28] កាណាដា[29] ចិន(ហុងកុង)[30] ចិន(ដីគោក)[31] អ៊ីតាលី[32] អាស៊ែបៃហ្សង់[33] រុស្ស៊ី[34] ស៊ុយអែត[35] និង ស្វ៊ីស[36]។

---

*McDermott*, អូស្ត្រាលី តុលាការសាទុក្ខព្រហ្មទណ្ឌ New South Wales, [2013] NSWCCA 102 (៦ ឧសភា ២០១៣) (ឧបសម្ព័ន្ធ១១)។

[25] នៅសហរដ្ឋអាមេរិក, តុលាការភាគច្រើនសឹងតែគ្រប់តុលាការសហព័ន្ធបានអនុវត្តតាមលទ្ធិបញ្ចប់នីតិវិធីចោទប្រកាន់ ដោយមរណភាពរបស់ជនជាប់ចោទ(the doctrine of abatement ab initio of the conviction) ដែលលុបចោលនូវរាល់ភស្តុតាងដែលធ្លាប់មានចំពោះការចោទប្រកាន់។ យុត្តាធិការខ្លះអនុវត្តទម្រង់នៃលទ្ធិខាងលើដោយធូរលុង ដោយមានតែការចោទប្រកាន់ទេដែលត្រូវបញ្ចប់ តែការសម្រេចពាក់ព័ន្ធនឹងសំណង (restitution order) មិនបញ្ចប់នោះទេ។ *មើល* SabrinaM.Bierer, *កត្តាសំខាន់នៃការសន្សំ: តើការបញ្ចប់ក្រោយពីមរណភាពនៃបុគ្គលពាក់ព័ន្ធដែលធ្វើឱ្យប៉ះពាល់ដល់អ្នកផានាគ្រួសារ និងសង្គម ជាទូទៅ*78Brook. L. Rev. (2013) ("Biererកត្តាសំខាន់នៃការសន្សំ") ទំព័រ ១៧៣៩ - ១៧៤០ និង Timothy A. Razel, *សេចក្តីស្លាប់ដើម្បីគេចចេញ: តើលទ្ធិដែលបញ្ចប់នីតិវិធីរាំងយុត្តិធម៌ដោយបែបណាខ្លះ - និងតើគួរធ្វើបែបណាវិញ* 75 Fordham L. Rev. 2193 (2007) ទំព័រ ២២០៨**(ឧបសម្ព័ន្ធ ១២, ១៣)**។

[26]អង់គ្លេស និង Wales *ច្បាប់សាទុក្ខព្រហ្មទណ្ឌ* ឆ្នាំ១៩៦៨ ចំណុច 44(A)(1) : "នៅពេលដែលបុគ្គលមួយបានទទួលមរណភាព (ក) រាល់បណ្តឹងសាទុក្ខពាក់ព័ន្ធអាចចាប់ផ្តើមដោយបុគ្គលនោះនាពេលនៅមានជិវិត ឬ អាចចាប់ផ្តើមដោយបុគ្គលណាមួយដែលទទួលការអនុញ្ញាតដោយសាលាសាទុក្ខ និង (ខ) នៅពេលដែលបណ្តឹងសាទុក្ខ ពាក់ព័ន្ធត្រូវបានចាប់ផ្តើមដោយបុគ្គលនោះនៅពេលមានជិវិត ឬ ត្រូវបានចាប់ផ្តើមពាក់ព័ន្ធនឹងសំណុំរឿងរបស់គាត់ ដោយបុគ្គលណាមួយដែលទទួលការអនុញ្ញាតពីសាលាសាទុក្ខ ឬ ដោយយោងគណៈកម្មការពិនិត្យសំណុំរឿងព្រហ្មទណ្ឌ ហើយរាល់នីតិវិធីបន្តទៅមុខទៀតដែលអាចនឹងធ្វើដោយបុគ្គលនោះនាពេលនៅរស់ អាចនឹងត្រូវបានធ្វើឡើងដោយបុគ្គលដែលទទួលការអនុញ្ញាត"**(ឧបសម្ព័ន្ធ ១៤)**។

[27]សិង្ហបុរី *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា 393 "នៅពេលដែលបុគ្គលមួយបានទទួលមរណភាព (ក) រាល់បណ្តឹង សាទុក្ខពាក់ព័ន្ធដែលអាចចាប់ផ្តើមដោយបុគ្គលនោះប្រសិនបើគាត់នៅមានជិវិតអាចត្រូវចាប់ផ្តើមដោយបុគ្គលដែលទទួលបានការអនុញ្ញាតពីតុលាការកំពូល និង (ខ) នៅពេលដែលរាល់បណ្តឹងសាទុក្ខពាក់ព័ន្ធត្រូវបានចាប់ផ្តើមដោយ បុគ្គលនោះនៅពេលដែលគាត់នៅមានជិវិត ឬ ត្រូវបានចាប់ផ្តើមឡើងពាក់ព័ន្ធនឹងករណីចំណុច (ក) ខាងលើ រាល់ដំណើរការបន្តទៅមុខទៀតដែលអាចធ្វើដោយបុគ្គលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខពេលគាត់នៅមានជិវិតអាចនឹង ត្រូវធ្វើឡើងដោយបុគ្គលដែលទទួលបានការអនុញ្ញាត"**(ឧបសម្ព័ន្ធ ១៥)**
។

[28]វិធាន ៤៣ (ការជំនួសភាគី) នៃ *វិធាននៃនីតិវិធីព្រហ្មទណ្ឌរបស់សហរដ្ឋអាមេរិក ២០១៦* អនុញ្ញាតឱ្យមានអ្នកជំនួស ដើមបណ្តឹងសាទុក្ខដែលទទួលមរណភាពនៅក្នុងដំណាក់កាលសាទុក្ខ (**ឧបសម្ព័ន្ធ ១៦**)។ វិធាននេះត្រូវបានប្រើប្រាស់ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ *មើល ឧ.ហរដ្ឋ v. Webb*សហរដ្ឋអាមេរិក តុលាការកំពូលនៃវ៉ាស៊ីនតោន 218 P.3d 695 (២៩ តុលា ២០០៩) ("*US, រដ្ឋ v. Webb*") (**ឧបសម្ព័ន្ធ ១៧**); *រដ្ឋ v. McGettrick*សហរដ្ឋអាមេរិក តុលាការកំពូលនៃរដ្ឋ Ohio 31 Ohio St. 3d 138 (២៤ មិថុនា ១៩៨៧) "វាស្ថិតនៅក្នុងផលប្រយោជន៍របស់ចុងចោទ ទ្រព្យ និង សង្គមរបស់ចុងចោទ នាពេលដែលបណ្តឹង

សុំឲ្យពិនិត្យចំពោះភាពមិនប្រក្រតីនៃនីតិវិធីដែលធ្វើឡើងដោយចុងចោទ ត្រូវបានពិនិត្យយ៉ាង ពេញលេញនិងសម្រេចដោយនីតិវិធីសាទុក្ខ [សេចក្តីយោងត្រូវបានលុបចោល]។App. R. 29(A) មានន័យថា ផលប្រយោជន៍បែបនេះត្រូវតែទទួលការការពារជាចាំបាច់។ App. R. 29(A) ជាដំបូងបានចែងដោយផ្នែកថា "ប្រសិន បើភាគីបានទទួលមរណភាពបន្ទាប់ពីទទួលសេចក្តីជូនដំណឹងអំពីការដាក់បណ្តឹងសាទុក្ខ ឬ ក្នុងអំឡុងពេលដែល នីតិវិធីមួយកំពុងដំណើរការក្នុងតុលាកាសាទុក្ខ អ្នកតំណាងផ្ទាល់ខ្លួននៃភាគីដែលទទួលមរណភាពអាចជំនួស ក្នុង នាមជាភាគី ស្របតាមញត្តិរបស់អ្នកតំណាងឬដោយភាគីណាមួយដែលបានដាក់នៅនឹងក្រឡាបញ្ជីនៃតុលាការ សាទុក្ខ" (ការបញ្ជាក់បន្ថែមមានភ្ជាប់មកជាមួយ) [...] ស្របជាមួយគ្នានេះ យើងបកស្រាយផ្នែក App. R. 29(A) ថា នៅពេលដែលមានចុងចោទក្នុងបទល្មើសព្រហ្មទណ្ឌដែលដាក់ពាក់បណ្តឹងសាទុក្ខបានទទួលមរណភាព នៅក្នុងពេល ដែលបណ្តឹងសាទុក្ខរបស់គាត់កំពុងដំណើរការ និងបន្ទាប់មកនិងក្នុងអំឡុងពេលសមស្របណាមួយ អ្នកតំណាង ផ្ទាល់ខ្លួននៃបុគ្គលដែលទទួលមរណភាពត្រូវបានតែងតាំងឲ្យជំនួសក្នុងនាមជា ភាគីក្នុងញត្តិរបស់តំណាងនៃបញ្ញាញាតិ ឬរដ្ឋ ក្រោមចំណាត់ការដែលមានស្រាប់សម្រាប់សំណុំរឿង ហើយតុលាការសាទុក្ខត្រូវបន្តនីតិវិធី ដើម្បីសម្រេចលើ បណ្តឹងសាទុក្ខ"**(ឧបសម្ព័ន្ធ ១៨)**; *រដ្ឋ v. Makaila*សហរដ្ឋអាមេរិក តុលាការកំពូលនៃរដ្ឋ Hawaii 897 P.2d 967 (១៤ មិថុនា ១៩៩៥) **(ឧបសម្ព័ន្ធ ១៩)**;*រដ្ឋ v. McDonald*សហរដ្ឋអាមេរិក តុលាការកំពូលនៃរដ្ឋ Wisconsin 144 Wis. 2d 531 (១៦ មិថុនា ១៩៨៨) **(ឧបសម្ព័ន្ធ ២០)** ដែលតុលាការកំពូលនៃរដ្ឋ Wisonsin បានសម្រេចថា "ចុងចោទមានសិទ្ធិ ស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់ក្នុងការប្តឹងសាទុក្ខ [ដែល]ជាផ្នែកមួយនីសិទ្ធិរបស់ចុងចោទ ក្នុងការសម្រេចចុងក្រោយ ទៅលើអង្គសេចក្តីនៃរឿងក្តី។ វាដើរតួជាកិច្ចការពារក្នុងការការពារជនត្រូវចោទប្រឆាំងនឹងកំហុសនៃនីតិវិធី។ ចុងចោទ ដែលទទួលមរណភាពនៅពេលដែលនីតិវិធីសាទុក្ខកំពុងដំណើរការដោយមិនគិតអំពីហេតុនៃមរណភាព នឹងត្រូវទទួល កិច្ចការពារខាងលើដោយមិនមានការបន្ធូរបន្ថយនោះទេ។ ជាងនេះទៅទៀតដោយសារនីតិវិធីបន្ទាប់បន្សំអាចត្រូវ បានប៉ះពាល់ដោយនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះការចោទប្រកាន់ថា បុគ្គលមួយបានយកជិវិតបុគ្គលមួយទៀត វា ជាផលប្រយោជន៍របស់សង្គមក្នុងការទទួលបានការពិនិត្យឲ្យចប់សព្វគ្រប់នូវសារធាតុនៃនីតិវិធីព្រហ្មទណ្ឌ"។ ជាលទ្ធផល វាជាការពិចារណាថា ជនត្រូវចោទមួយរូបដែលបាន "ចាប់ផ្តើមនីតិវិធីសាទុក្ខដោយសមស្រប មុនមរណភាព របស់ខ្លួន [...] ត្រូវទទួលបានការសម្រេចចុងក្រោយទៅលើបណ្តឹងសាទុក្ខរបស់គាត់"។ *មើលផងដែរ* Bierre, កត្តាសំខាន់នៃការសន្សំ។

[29] ជាគោលការណ៍ នីតិវិធីព្រហ្មទណ្ឌបញ្ចប់ដោយមរណភាពរបស់ជនជាប់ចោទឬដើមបណ្តឹងសាទុក្ខ។ ទោះជាយ៉ាង ណាក៏ដោយ ប្រសិនបើពិរុទ្ធជនបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខមុនមរណភាពរបស់ខ្លួន ចៅក្រមមាន ឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើត្រូវបន្តដែរឬទេ។ វាមានពីរដំណាក់កាលដែលត្រូវធ្វើ ដើម្បីបន្តនីតិវិធីសាទុក្ខផ្នែក ព្រហ្មទណ្ឌបន្ទាប់ពីដើមបណ្តឹងសាទុក្ខបានទទួលមរណភាព ៖ ១) បុគ្គលណាមួយត្រូវចូលមកជំនួសកន្លែងរបស់ ដើមបណ្តឹងសាទុក្ខ ដោយដាក់ពាក្យសុំដូចកំណត់ក្នុង ចំណុច 73(1) នៃច្បាប់តុលាការកំពូលរបស់ប្រទេសកាណាដា និង ២) ការបន្តនីតិវិធីសាទុក្ខត្រូវធ្វើឡើងនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌។ ចំណុចទាំងពីរខាងលើត្រូវបំពេញដើម្បី ឲ្យនីតិវិធីបន្តចំពោះបណ្តឹងសាទុក្ខ **(ឧបសម្ព័ន្ធ ២១)**។ *មើលR. v. Jette*, កាណាដា តុលាការសាទុក្ខនៃទីក្រុង Quebec [1999] RJQ 2603 (១៨ តុលា ១៩៩៩) *(ឧបសម្ព័ន្ធ ២២)*; និង *R. v. Smith*, កាណាដា តុលាការ កំពូលនៃប្រទេសកាណាដា [2004] 1 SCR 385 (៤ មីនា ២០០៤) ("កាណាដា, *R. v. Smith*", **ឧបសម្ព័ន្ធ ២៣**)

[30] នៅហុងកុង នៅពេលដែលបណ្តឹងសាទុក្ខត្រូវបានចុះបញ្ជីនៅតុលាការនៃបណ្តឹងសាទុក្ខចុងក្រោយក្នុងពេលដែល ដើមបណ្តឹងសាទុក្ខនៅមានជិវិត វាជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការបន្តនីតិវិធីសាទុក្ខ ទោះដើមបណ្តឹងសាទុក្ខ ទទួលមរណភាពក៏ដោយ ដោយមានការជំនួស និងអាចនឹងលើកចោលការចោទប្រកាន់ដែលជាផលនៃមរណភាព។ *មើលHKSR v. Cheng Chee-Tock*

*Theodore,* ចិន តុលាការនៃបណ្តឹងសាទុក្ខចុងក្រោយនៃតំបន់រដ្ឋបាលពិសេសហុងកុង FACC No. 7/2014 (២៥ មិថុនា ២០១៥) ("ហុងកុង *HKSAR v. Cheng chee-Tock Theodore*") កថាខណ្ឌ ៣១ (**ឧបសម្ព័ន្ធ ២៤**)។

[31] មាត្រា 16(5) នៃច្បាប់នីតិវិធីព្រហ្មទណ្ឌចិន ចែងថា មរណភាពនឹងបញ្ចប់នីតិវិធីព្រហ្មទណ្ឌ**ប្រឆាំង**នឹងបុគ្គល ដែលទទួលមរណភាព។ ទោះជាយ៉ាងណាក៏ដោយ មាត្រា ២៩៧ បានចែងថា ប្រសិនបើមានភស្តុតាងបង្ហាញថា បុគ្គល ដែលទទួលមរណភាពមិនមានទោស តុលាការរបស់ប្រជាជនអាចបើកអង្គជំនុំជម្រះកំបាំងមុខ (**ឧបសម្ព័ន្ធ ២៥**)។ ជាង នេះទៅទៀត មាត្រា 241(9) នៃការបកស្រាយរបស់តុលាការកំពូលរបស់ប្រជាជនពាក់ព័ន្ធនឹងការអនុវត្តច្បាប់នីតិវិធី ព្រហ្មទណ្ឌ ចែងថា [ការបកប្រែផ្លូវការ] : " សម្រាប់រឿងក្តីដែលត្រូវបានចោទប្រកាន់នៅក្នុងដំណាក់កាលជំនុំជម្រះ ដំបូង" ប្រសិនបើចុងចោទបានទទួលមរណភាព តុលាការត្រូវចេញសេចក្តីសម្រេចបញ្ចប់ការវិនិច្ឆ័យ។ ទោះជាយ៉ាងណា ក៏ដោយ "ប្រសិនបើតុលាការមានជំនឿជឿជាក់ថា ចុងចោទមិនមានទោសដោយផ្អែកលើអង្គហេតុជាក់ច្បាស់និង ភស្តុតាងដែលទទួលបាន [តុលាការ]ត្រូវចេញសេចក្តីសម្រេចនិងប្រកាសថា ចុងចោទគ្មានទោស"(**ឧបសម្ព័ន្ធ ២៦**)។

[32] អ៊ីតាលី *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា 69(1) [ការបកប្រែមិនផ្លូវការ]: "ប្រសិនបើជនជាប់ចោទទទួលមរណភាព នៅក្នុងដំណាក់កាលណាមួយ និងការចាប់ផ្តើមនីតិវិធីដំបូងបន្ទាប់ពីការចោទប្រកាន់ព្រហ្មទណ្ឌចាប់ផ្តើម តុលាការ បន្ទាប់ពីស្តាប់ព្រះរាជអាជ្ញានិងមេធាវី ត្រូវផ្តល់សេចក្តីសម្រេចស្របតាម មាត្រា 129"។ មាត្រា 129(2) : "តុលាការត្រូវ ផ្តល់ដីកាសម្រេចថាគ្មានទោស ឬ ដោយគ្មានមូលដ្ឋានក្នុងការបន្តនីតិវិធីស្របតាមរូបមន្តដែលមានស្រាប់ ប្រសិនបើមាន ហេតុក្នុងការបញ្ចប់បទល្មើស ប៉ុន្តែមានការបញ្ជាក់ច្បាស់ថា សកម្មភាពនៃបទល្មើសមិនបានកើតឡើង ឬជនជាប់ចោទ មិនបានប្រព្រឹត្តបទល្មើស ឬសកម្មភាពមិនត្រូវបានចាត់ទុកថាជាបទល្មើស ឬវាមិនត្រូវចាត់ទុកថាជាបទល្មើសស្របតាម ច្បាប់"(**ឧបសម្ព័ន្ធ ២៧**)។

[33] អាស៊ែបៃហ្សង់*ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា 24(1)(4) [ការបកប្រែផ្លូវការ/មិនផ្លូវការ] : "ការចោទប្រកាន់ព្រហ្មទណ្ឌ ដែលមិនអាចចាប់ផ្តើមឬត្រូវបញ្ឈប់ (និងរឿងក្តីព្រហ្មទណ្ឌមិនអាចត្រូវបានចាប់ផ្តើម ឬនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌត្រូវ បញ្ឈប់) នៅក្នុងករណីដូចតទៅ: [...] 39.1.5. ប្រសិនបើបុគ្គលទទួលមរណភាពបន្ទាប់ពីធ្វើសកម្មភាពដេលមានកំណត់ ក្នុងច្បាប់ព្រហ្មទណ្ឌ (លើកលែងករណីដែលចាំបាច់ក្នុងការលើកលែងការចោទប្រកាន់លើបុគ្គលនោះ)"(**ឧបសម្ព័ន្ធ ២៨**)។

[34] រុស្ស៊ី *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា 24(1)(4) [ការបកប្រែផ្លូវការ/មិនផ្លូវការ] : "រឿងក្តីព្រហ្មទណ្ឌមួយមិនអាចចាប់ ផ្តើម ឬការចាប់ផ្តើមរឿងក្តីព្រហ្មទណ្ឌត្រូវបញ្ចប់ដោយហេតុផលដូចតទៅ : [...] ការស្លាប់របស់ជនសង្ស័យឬជន ជាប់ចោទ ដោយលើកលែងករណីដែលនីតិវិធីនៅលើរឿងក្តីព្រហ្មទណ្ឌមានភាពចាំបាច់សម្រាប់ការស្តារឡើងវិញនូវ បុគ្គលដែលទទួលមរណភាព"។ មាត្រា 5(34) : "ការស្តារឡើងវិញ - នីតិវិធីនៃការបញ្ចូលបុគ្គលដែលត្រូវបានចោទពី បទល្មើសព្រហ្មទណ្ឌដោយខុសច្បាប់ឬគ្មានសំអាង នូវសិទ្ធិនិងសេរីភាពនិងចំពោះសំណងនៃផលប៉ះពាល់ដល់រូប គាត់" (**ឧបសម្ព័ន្ធ ២៩**)។

[35] ស៊ុយអែត *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៣៨២(៣) [ការបកប្រែផ្លូវការ/មិនផ្លូវការ] ; "ការរស់រានមានជីវិតរបស់ សហព័ទ្ធ អ្នកទទួលមរតកដោយផ្ទាល់ ឪពុក ម្តាយ ឬបងប្អូន របស់ជនសង្ស័យដែលបានស្លាប់ អាចប្តឹងសាទុក្ខ ចំពោះសាលក្រមក្នុងដែនកំណត់ដែលសាលក្រមនោះត្រូវបានប្រកាសថា ជនសង្ស័យបានប្រព្រឹត្តអំពើ" (**ឧបសម្ព័ន្ធ ៣០**)។

[36] ស្វីស *ក្រមនីតិវិធីព្រហ្មទណ្ឌ* ជំពូក ២១ ផ្នែក ១ [ការបកប្រែផ្លូវការ/មិនផ្លូវការ] : "ក្នុងករណីមរណភាពរបស់ជនជាប់ចោទ បុគ្គលដែលត្រូវបានកាត់ទោសឬពាក្យបណ្តឹងឯកជននៃបច្ចាញាតិបន្ទាប់ស្របតាម ប្រការ ១១០ កថាខណ្ឌ ១ SCC158 និងស្របតាមលំដាប់នៃច្បាប់មរតក អាចស្វែងរកសំណងបណ្តឹងសាទុក្ខ ឬ បន្តនីតិវិធីសាទុក្ខ នៅពេល ដែលផលប្រយោជន៍ស្របច្បាប់ត្រូវរងការប៉ះពាល់"(**ឧបសម្ព័ន្ធ ៣១**)។

៣២. ជាភស្តុតាងមួយដែរ ដែលនៅក្នុងយុត្តាធិការដែលទទួលស្គាល់សិទ្ធិសន្មត់ជាមុនថាគ្មានទោស នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ប្រសិទ្ធិភាពផ្លូវច្បាប់នៃការបញ្ចប់តែងតែធ្វើឲ្យសាលក្រមសាលាដំបូងអស់អានុភាពអនុវត្ត ដោយដើមបណ្តឹងសាទុក្ខដែលបានទទួលមរណភាពនៅតែត្រូវសន្មត់ជាមុនថាគ្មានទោស។[37]

៣៣. ជារួម ក្រៅពីការខ្វះខាតនៃវិធានរួម សេចក្តីសន្និដ្ឋានអាចធ្វើបានពីការស្ទង់មតិរបស់មេធាវីការពារក្តី ដោយការបញ្ចប់នីតិវិធីគឺជាជម្រើសមួយសម្រាប់តុលាការ នៅពេលដើមបណ្តឹងសាទុក្ខបានទទួលមរណភាព។ នៅក្នុងយុត្តាធិការខ្លះ តុលាការមានជម្រើសផ្សេងក្នុងការបន្តនីតិវិធីសាទុក្ខ ដោយផ្អែកលើមូលដ្ឋានពិសេស។ នៅក្នុងហេតុការណ៍ណាក៏ដោយ ក្នុងបណ្តាយុត្តាធិការដែលទទួលស្គាល់ការបន្តការសន្មត់ជាមុនថាគ្មានទោសនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ឥទ្ធិពលនៃការបញ្ចប់នីតិវិធីមានសារៈសំខាន់ ក្នុងការធ្វើឲ្យសាលក្រមសាលាដំបូងអស់អានុភាពអនុវត្ត។

៣៤. វត្តមានរបស់វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដូចបានបកស្រាយនៅក្នុង ផ្នែក II ខាងលើ បានបង្ហាញថា (ក) អ.វ.ត.ក ទទួលស្គាល់សិទ្ធិសន្មត់ជាមុនថាគ្មានទោស នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ និង (ខ) ការទទួលមរណភាពនាពេលណាមួយរបស់ដើមបណ្តឹងសាទុក្ខគឺជាហេតុផលក្នុងការបញ្ចប់នីតិវិធីព្រហ្មទណ្ឌ ដែលនាំឲ្យសាលក្រមសាលាដំបូងអស់អានុភាពអនុវត្ត។

## គ. វិធានដែលបង្កើតឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ICTY (នៅក្នុងសំណុំរឿង Delic ) មិនបានផ្តល់ការណែនាំត្រឹមត្រូវ ដល់ អ.វ.ត.ក

[37] នៅប្រទេសបារាំង សច្ចធារណ៍នៃនិរទោសអនុវត្តនៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ រួមទាំងសាទុក្ខ។ *មើល* ប្រទេសបារាំង *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រាដើម (III) និង មាត្រា ៣២៧(៤)។ នៅប្រទេសផ្សេងទៀតជាច្រើន ទាំងប្រព័ន្ធច្បាប់ស៊ីវិលនិងប្រព័ន្ធច្បាប់ common law សច្ចធារណ៍នៃនិរទោសអនុវត្តក្នុងដំណាក់កាលនីតិវិធី ព្រហ្មទណ្ឌ។ ឧ.ហ អ៊ីតាលី *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៦៤៨ [ការបកប្រែផ្លូវការ] ៖ "សាលក្រមចូលជាស្ថាពរនា ពេលដែលរាល់សិទ្ធិទាមទារត្រូវបានផុតកំណត់ និងពេលវេលាកំណត់នៃការប្តឹងសាទុក្ខត្រូវបានផុតកំណត់"; *រដ្ឋធម្មនុញ្ញនៃសហរដ្ឋអ៊ីតាលី*, មាត្រា ២៧(២) [ការបកប្រែផ្លូវការ] : "ជនជាប់ចោទមិនត្រូវបានចាត់ទុកថាមានទោស រហូតដល់សាលក្រមចូលជាស្ថាពរ"(**ឧបសម្ព័ន្ធ ៣២**); បូស្នី និងHerzegovina, *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៣ [ការបកប្រែមិនផ្លូវការ] : បុគ្គលត្រូវចាត់ទុកថាគ្មានទោស "រហូតដល់ទោសត្រូវបានបង្កើតដោយសាលក្រមស្ថាពរ"; និង មាត្រា ១៧៨(១) [ការបកប្រែមិនផ្លូវការ] : "សាលក្រមត្រូវចូលជាស្ថាពរនាពេលដែលវាមិនអាចតវ៉ាដោយបណ្តឹង សាទុក្ខ ឬ នាពេលដែលគ្មានបណ្តឹងសាទុក្ខណាដែលអាចទទួលយកបាន"។

៣៥. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺជាអង្គជំនុំជម្រះអន្តរជាតិដំបូង ដែលបានដោះស្រាយស្ថានភាពដែលដើមបណ្តឹងសាទុក្ខបាន ទទួលមរណភាពមុនសេចក្តីសម្រេច សាទុក្ខត្រូវបានប្រកាស។ ករណីនេះកើតឡើងនៅពេលដែល ដើមបណ្តឹងសាទុក្ខ Rasim Delic បានទទួលមរណភាពនៅក្នុងអំឡុងពេលនីតិវិធីសាទុក្ខក្នុងឆ្នាំ ២០១០។ អង្គជំនុំជម្រះកំពូលបាន ច្រានចោលជំហររួមគ្នារបស់អង្គភាពការពារក្តីរបស់ Delic[38] និងព្រះរាជអាជ្ញា[39] លើការបន្តនីតិ វិធីសាទុក្ខបន្ទាប់ពីមរណភាពរបស់ Delic។[40] អង្គជំនុំជម្រះកំពូលបានសម្រេចបញ្ចប់នីវិធីសាទុក្ខ ពាក់ព័ន្ធនឹង Delic និងប្រកាសឲ្យចូលជាស្ថាពរនូវសាលក្រមសាលាដំបូងប្រឆាំងនឹង Delic។[41]

៣៦. ដូចបានបង្ហាញខាងក្រោម វិធានដែលបង្កើតឡើងដោយអង្គជំនុំជម្រះកំពូលរបស់ តុលាការព្រហ្ម ទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុង សំណុំរឿង Delic គឺមិនត្រឹមត្រូវតាមផ្លូវ ច្បាប់ និង នៅក្នុងហេតុការណ៍ណាក៏ដោយយ មិនអាចអនុវត្ត បានចំពោះ អ.វ.ត.ក នោះទេ។

## ១. អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY)បានប្រព្រឹត្តកំហុសផ្លូវច្បាប់ ដោយរកឃើញថាការសន្និដ្ឋានជាមុនថាគ្មានទោស ពុំ អាចអនុវត្តនៅក្នុងបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី

៣៧. គោលការណ៍របស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី ដែលលើកឡើងថា នីតិវិធីបណ្តឹងសាទុក្ខត្រូវតែបញ្ចប់ដាច់ខាត បន្ទាប់ពីដើម បណ្តឹងសាទុក្ខបានទទួលមរណភាព ហើយការបញ្ចប់នីតិវិធីដែលធ្វើឲ្យសាលក្រមរបស់សាលា ដំបូងស្ថាពរ គឺសុទ្ធតែការប្រព្រឹត្តកំហុស។ សម្រាប់គោលបំណងនៃផ្នែកនេះ ក្រុមមេធាវីការពារក្តី

---

[38] *ព្រះរាជអាជ្ញា v. Delic*, IT-04-83-A, “សេចក្តីជូនដំណឹងផ្លូវការនៃមរណភាពនិងញត្តិស្នើសុំបន្តនីតិវិធីសាទុក្ខ” ២១ មេសា ២០១០, កថាខណ្ឌ ៧។

[39] *ព្រះរាជអាជ្ញា v. Delic*, IT-04-83-A, “ចម្លើយតបទៅនឹងញត្តិស្នើសុំបន្តនីតិវិធីសាទុក្ខ” ២៨ មេសា ២០១០, កថាខណ្ឌ ១៦។

[40] សេចក្តីសម្រេច Delic លើលទ្ធផលនីតិវិធី។

[41] សេចក្តីសម្រេច Delic លើលទ្ធផលនីតិវិធី, កថាខណ្ឌ ១៦។

នឹងលើកយកមកពិភាក្សានូវចំណុចដែលបានលើកឡើងរួចមកហើយ។ ចំណុចដែលមិនត្រឹមត្រូវ នឹងត្រូវលើកយកមកពិភាក្សានៅចំណុចទី៤ ផ្នែកទីIV- ខ។

៣៨. ការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូលដែលថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នឹងក្លាយជាសាលក្រមស្ថាពរ បន្ទាប់ពីមានការបញ្ចប់នីតីវិធីបណ្តឹងសាទុក្ខ ក្រោយការស្លាប់របស់ដើមបណ្តឹងសាទុក្ខ យោងទៅលើសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "ការសន្មត់ជាមុនថាគ្មានទោសមិនអាចអនុវត្តចំពោះពិរុទ្ធជន ដែលត្រូវបានអង្គជំនុំជម្រះផ្តន្ទាទោសរួចហើយ ខណៈពេលរង់ចាំនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ឡើយ"។[42]

៣៩. ការបកស្រាយបែបនេះ ពុំមានអំណះអំណាងនៅក្នុងលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឬវិធានច្បាប់ និងភស្តុតាងឡើយ។ ការបកស្រាយបែបនេះក៏បំពានទៅលើវិធានមូលដ្ឋាននៃការបកស្រាយដូចជា គោលការណ៍ប្រសិទ្ធិភាពជាដើម។ តុលាការសិទ្ធិមនុស្សតំបន់អឺរ៉ុបបានលើកឡើងថា៖

> តុលាការក៏បានបញ្ជាក់ជាថ្មីម្តងទៀតថា អនុសញ្ញា **ត្រូវតែបកស្រាយក្នុងបទដ្ឋានដែលធានាដល់សិទ្ធិដែលអាចអនុវត្តបាន និងប្រកបដោយប្រសិទ្ធិភាព** ផ្ទុយនឹងទ្រឹស្តី និងភាពស្រមើលស្រមៃ [...]។ ដូច្នេះ នៅដំណាក់កាលបន្ទាប់ តុលាការយល់ឃើញថា **ការសន្មត់ជាមុនថាគ្មានទោស មិនអាចផ្អាកការអនុវត្តក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍បានឡើយ ដោយហេតុថាជនជាប់ចោទត្រូវបានរកឃើញថាមានទោសដោយសាលាដំបូង។ សេចក្តីសម្រេចបែបនេះផ្ទុយនឹងមុខងារនៃបណ្តឹងឧទ្ធរណ៍** ដោយហេតុថា បណ្តឹងឧទ្ធរណ៍ តឹតម្រូវឲ្យមានការត្រួតពិនិត្យឡើងវិញនូវសេចក្តីសម្រេចពីពេលមុន ទាំងលើអង្គហេតុ និងអង្គច្បាប់។ មានន័យថា ការសន្មត់ជាមុនថាគ្មានទោស ពុំអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធី បញ្ជូន

[42] សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង *Delić* កថាខណ្ឌ១៤។

មកដើម្បីត្រួតពិនិត្យឡើងវិញលើសំណុំរឿង និងមានការផ្តន្ទាទោសកាលពីពេលមុនរួចហើយ។[43]

៤០. ក្នុងការព្យាយាមធ្វើយុត្តិកម្មលើការបកស្រាយរបស់ខ្លួន ដែលថា ការសន្មត់ជាមុនថាគ្មានទោសមិនអាចអនុវត្តចំពោះពិរុទ្ធជននៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានកំណត់ថា ការបកស្រាយនេះស៊ីសង្វាក់គ្នានឹងបទដ្ឋាននៃការត្រួតពិនិត្យឡើងវិញលើការអនុវត្ត "ភាគីនៃបណ្តឹងឧទ្ធរណ៍មានកាតព្វកិច្ចបង្ហាញនូវកំហុសអង្គច្បាប់ ឬអង្គហេតុ [...] ជាជាងការព្យាយាមផ្តួចផ្តើមឲ្យមានសវនាការជាថ្មីឡើងវិញ"។[44]

៤១. ការលើកឡើងនេះមានភ្ជាប់នូវកំហុសចំនួនពីរបន្តទៀត។ ទីមួយ ដើមបណ្តឹងសាទុក្ខ ពុំមានកាតព្វកិច្ចក្នុងការបង្ហាញកំហុសនោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីឡើយ។ វាត្រូវបានបង្កើតឡើងថា "បើទោះបីជាការលើកអំណះអំណាងរបស់ភាគីមិនគ្រប់គ្រាន់ដើម្បីគាំទ្រទឡ្ហីករណ៍នៃកំហុសក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលនៅតែអាចសន្និដ្ឋានចំពោះសំអាងហេតុផ្សេងទៀតដែលចាត់ទុកថាជាកំហុសអង្គច្បាប់។[45]

៤២. ទីពីរ ការណ៍ដែលមិនបើកសវនាការជាថ្មីឡើងវិញ ពុំមែនមានន័យថាអង្គជំនុំជម្រះតុលាការកំពូលមិនអាចរកឃើញអង្គហេតុឲ្យបានសមស្របតាមបទដ្ឋាននៃការបង្ហាញភស្តុតាង ដូចអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ប្រការនេះគឺជាយុទ្ធសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលថា៖

> [...] អង្គជំនុំជម្រះតុលាការកំពូលមិនត្រឹមតែកែតម្រូវទៅលើកំហុសផ្នែកច្បាប់នោះទេ ប៉ុន្តែក្នុងករណីចាំបាច់ គឺអនុវត្តបទដ្ឋានច្បាប់សមស្រប ដើម្បីឲ្យភស្តុតាងដែលមាននៅក្នុងកំណត់ត្រាសវនាការ និងពិចារណាថា តើខ្លួនពិតជាយល់ស្របតាមការបង្ហាញឲ្យ

[43] សំណុំរឿងលេខ ៥៣៤៦៦/០៧ *Kontas ទល់នឹង ប្រទេសក្រិក* តុលាការសិទ្ធិមនុស្សតំបន់អឺរ៉ុប "ការដកស្រង់ពីសាលក្រម" ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ (**ឯកសារភ្ជាប់លេខ ៣៣**) កថាខណ្ឌ ៣៦ (emphasis added)។

[44] សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង *Delić* កថាខណ្ឌ១៤។

[45] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង KrajiÈnik* លេខ IT-00-39-A សាលក្រម ថ្ងៃទី១៥ មិនា ឆ្នាំ២០០៩ " *សាលក្រមបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង KrajiÈnik* " កថាខណ្ឌ ១២ (emphasis added)។

ឬសពីវិមតិសង្ស័យដូចការរកឃើញចេញពីអង្គហេតុដែលត្រូវបានលើកឡើងដោយដើមបណ្ដឹងសាទុក្ខ នៅចំពោះមុខការរកឃើញ ដែលត្រូវបានបញ្ជាក់នៅក្នុងបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលនឹងមិនសើរើឡើងវិញលើកំណត់ត្រាក្នុងសវនាការទាំងមូលនោះទេ។[46]

៤៣. យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូល របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានប្រព្រឹត្តកំហុស ដោយការរក្សាជំហរថាការសន្មត់ជាមុនថាគ្មានទោស ត្រូវផ្អាកការអនុវត្តចំពោះពិរុទ្ធជនបន្ទាប់ពីមានការផ្តន្ទាទោសនៅអង្គជំនុំជម្រះសាលាដំបូង។

## ២. ក្នុងករណីណាក៏ដោយសេចក្ដីសម្រេចក្នុងសំណុំរឿង *Delić* មិនអាចអនុវត្តនៅ អ.វ.ត.ក បានឡើយ

៤៤. ដោយឡែក ភាពត្រឹមត្រូវនៃសេចក្ដីសម្រេចក្នុងសំណុំរឿង *Delić* ច្បាប់បានបង្កើតនៅក្នុងសេចក្ដីសម្រេចនេះថា សាលក្រមរបស់សាលាដំបូង នឹងក្លាយជាស្ថាពរ បន្ទាប់ពីនីតិវិធីបណ្ដឹងសាទុក្ខត្រូវបានបញ្ចប់ ក្រោយពេលមរណៈភាពរបស់ជនជាប់ចោទនោះ គឺមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ។

៤៥. ផ្ទុយពីលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលពុំមានការបង្ហាញថា ការសន្មត់ជាមុនថាគ្មានទោស អាចអនុវត្តចំពោះបណ្ដឹងសាទុក្ខឬក៏អត់នោះ ឯកសារច្បាប់របស់ អ.វ.ត.ក ដូចដែលបានពន្យល់ពីខាងដើមពិតជាបង្ហាញយ៉ាងច្បាស់ថាករណីនេះអាចអនុវត្តបាន។

៤៦. ដូច្នេះ វិធាននៅក្នុងសំណុំរឿង *Delić* ដែលអះអាងថាការសន្មត់ជាមុនថាគ្មានទោសមិនអាចអនុវត្តនៅអង្គជំនុំជម្រះតុលាការកំពូលគឺមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ។ នៅ អ.វ.ត.ក

[46] សាលដីកានៃបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង *KrajiÈnik* កថាខណ្ឌ១៣។

ការសន្មត់ជាមុនថាគ្មានទោសគឺអាចបន្តអនុវត្តនៅក្នុងដំណាក់កាលនីតិវិធីបណ្តឹងសាទុក្ខ ខណៈពេលកំពុងរង់ចាំសាលដីកាពីអង្គជំនុំជម្រះតុលាការកំពូល។

៤៧. សរុបមក យោងទៅលើវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មរណភាពនៃដើមបណ្តឹងសាទុក្ខគឺជាមូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ ហើយសាលក្រមរបស់សាលាដំបូងប្រឆាំងនឹងដើមបណ្តឹងសាទុក្ខដែលទទួលមរណភាព ត្រូវអស់អានុភាពអនុវត្ត។ ការបកស្រាយច្បាប់ដែលមានស្រាប់នេះ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋានអន្តរជាតិ ជាក់ស្តែង គឺគោលការណ៍សច្ចធារណ៍នៃនិរទោស។

## IV. អង្គជំនុំជម្រះ គួរមានជម្រើសផ្សេងទៀត ដើម្បីផលប្រយោជន៍យុត្តិធម៌ ដើម្បីបន្តនីតិវិធីបណ្តឹងសាទុក្ខ បើទោះជាដើមបណ្តឹងសាទុក្ខបានទទួលមរណភាពក៏ដោយ

៤៨. ដូចដែលបានបកស្រាយខាងលើរួចមកហើយ ក្រៅពីការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ មានយុត្តាធិការក្នុងស្រុកជាច្រើនដែលប្រមើលមើលពីជម្រើសផ្សេងទៀតដើម្បីបន្តនីតិវិធីបណ្តឹងសាទុក្ខបន្ទាប់ពីមរណភាពរបស់ដើមបណ្តឹងសាទុក្ខ។ វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពុំមានចែងអំពីជម្រើសនេះទេ។

៤៩. នៅក្នុងផ្នែកនេះ មេធាវីការពារក្តីនឹងបង្ហាញថា៖ (ក) ការមានជម្រើសបែបនេះ មានភាពសមស្របនឹងបទដ្ឋានអន្តរជាតិ (ជាក់ស្តែងគឺដើម្បីផលប្រយោជន៍យុត្តិធម៌) ហើយមួយផ្នែកទៀតជាការឆ្លុះបញ្ចាំងពីច្បាប់នៃយុត្តាធិការក្នុងស្រុក (ផ្នែកទីIV-ក និង IV-គ) (ខ) វិធានជាក់លាក់នៃការបញ្ចប់នីតិវិធីនៅក្នុងសំណុំរឿង *Delić* គឺផ្អែកទៅលើមូលដ្ឋានច្បាប់ដែលមិនត្រឹមត្រូវ និងមិនអាចអនុវត្តនៅអ.វ.ត.ក (ផ្នែកទីIV-ខ) និង (គ)អង្គជំនុំជម្រះនេះមានសិទ្ធិអំណាចក្នុងការបង្កើតវិធានថ្មី ឬក៏ស្នើរសុំធ្វើវិសោធនកម្មវិធាន ដើម្បីបង្កើតជម្រើសផ្សេង ដែលមិនផ្ទុយនឹងច្បាប់ដែលមានស្រាប់ (ផ្នែក IV-ឃ និង IV-ង)។

### ក. ច្បាប់ជាតិរបស់ប្រទេសមួយចំនួន មានមូលដ្ឋានច្បាប់ដែលអនុញ្ញាតឲ្យបន្តនីតិវិធីបណ្តឹងសាទុក្ខបន្ទាប់ពីមរណភាពនៃដើមបណ្តឹងសាទុក្ខ

៥០. ដូចដែលបានបញ្ជាក់រួចមកហើយនៅផ្នែកទីIII-ខ មានយុត្តាធិការក្នុងស្រុកជាច្រើន ដែលទទួលស្គាល់ភាពចាំបាច់តម្រូវឱ្យមានជម្រើស សម្រាប់បន្តនីតិវិធីបណ្ដឹងសាទុក្ខបន្ទាប់ពីមរណភាពរបស់ដើមបណ្ដឹងសាទុក្ខ បន្ថែមលើការបញ្ចប់នីតិវិធី។

៥១. ក្នុងចំណោមយុត្តាធិការទាំងនោះ មានយុត្តាធិការមួយចំនួនអនុញ្ញាតឱ្យសាច់ញាតិជិតស្និទ្ធរបស់ដើមបណ្ដឹងសាទុក្ខដែលទទួលមរណភាព ឬក៏ពិរុទ្ធជនដែលទទួលការផ្ដន្ទាទោស ដើម្បីប្ដឹងសាទុក្ខ ឬបន្តនីតិវិធីបណ្ដឹងសាទុក្ខប្រឆាំងនឹងការផ្ដន្ទាទោស ក្នុងនាមជនដែលបានទទួលមរណភាព។[47] ប្រទេសមួយចំនួនទៀត អនុញ្ញាតឱ្យបន្តនីតិវិធីបណ្ដឹងសាទុក្ខ ជំនួសបន្ទាប់ពីជនជាប់ចោទបានទទួលមរណភាព ឬក៏តាមរយៈសាច់ញាតិ ឬក៏ជនណាដែលជនជាប់ចោទបានផ្ទេរសិទ្ធិឱ្យ។[48] មួយចំនួនទៀត ទាមទាឱ្យមានការបន្តនីតិវិធីបណ្ដឹងសាទុក្ខ ខណៈពេលដែលមានភស្តុតាងបង្ហាញថាជនជាប់ចោទពុំមានពិរុទ្ធភាព។[49]

៥២. បើទោះបីជាមានលក្ខណៈលម្អិតផ្សេងៗគ្នាក៏ដោយ ហេតុផលចាំបាច់រួមមួយចំនួនអាចដកស្រង់ចេញពីច្បាប់នៅក្នុងស្រុកទាំងនេះ។ ឧទាហរណ៍ ភាពចំបាច់ ស្ដារកេរ្តិ៍ឈ្មោះលើភាពគ្មានទោសរបស់ទណ្ឌិត ដែលត្រូវបានកាត់ទោសដោយមិនត្រឹមត្រូវ នៅតែមានបន្ទាប់ពីជននោះទទួលមរណភាព ហើយដើម្បីជាមូលដ្ឋានយុត្តិធម៌ គឺតម្រូវឱ្យមានការកែប្រែនូវការផ្ដន្ទាទោសដែលមិនត្រឹមត្រូវ បើទោះបីជាពិរុទ្ធជននោះនៅរស់រានមានជីវិតក៏ដោយ។ ការអនុវត្តបែបនេះមានន័យថា យុត្តាធិការនៅតុលាការកំពូលតម្រូវឱ្យនៅបន្តនីតិវិធី ខណៈពេលដែលមានភស្តុតាងបញ្ជាក់ពីភាពគ្មានទោស

---

[47] ប្រទេសស៊ុយអែត *ក្រមនីតិវិធីច្បាប់* ជំពូក២១ ផ្នែក១; ប្រទេសស្វីស *ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៣៨២(៣)។

[48] ប្រទេសអង់គ្លេស និងប្រទេសវែល *Criminal Appeal Act* 1968 ផ្នែក៤៤ក; ប្រទេសសិង្ហបុរី ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៣; សហរដ្ឋអាមេរិក *នីតិវិធីព្រហ្មទណ្ឌនៃច្បាប់សហព័ន្ធឆ្នាំ២០១៦* មាត្រា៤៣; សហរដ្ឋអាមេរិក សំណុំរឿង *រដ្ឋអង្គា ទល់នឹង Webb* ; ប្រទេសកាណាដា សំណុំរឿង *R ទល់នឹង Smith* កថាខណ្ឌ១០; សំណុំរឿង *រដ្ឋាភិបាលតំបន់រដ្ឋបាលពិសេសហុងកុង ទល់នឹង Cheng Chee-Tock Theodore* កថាខណ្ឌ៣១-៣៤ និង ៣៩-៤២។

[49] ប្រទេសអ៊ីតាលី ក្រមព្រហ្មទណ្ឌ មាត្រា ៦៩(១) និង ១២៩(២); Azerbaijan ក្រមព្រហ្មទណ្ឌ មាត្រា ៣៩.១.៥; ប្រទេសរុស្ស៊ី ក្រមព្រហ្មទណ្ឌ មាត្រា ២៤(១)(៤) និង ៥(៣៤); សាធារណរដ្ឋប្រជាមានិតចិន ក្រមព្រហ្មទណ្ឌ២០១៨ មាត្រា២៩៧(១) [ការបកប្រែផ្លូវការ និងមិនផ្លូវការ] "នៅពេលជនជាប់ចោទបានស្លាប់បាត់បង់ជីវិត តុលាការមានសិទ្ធិបញ្ចប់នីតិវិធី។ ក៏ប៉ុន្តែ ប្រសិនបើ មានភស្តុតាងបញ្ជាក់ថា ជនជាប់ចោទមិនមានទោស ហើយតុលាការយល់ឃើញជនជាប់ចោទពិតជាមិនមានទោសមែន តាមរយៈសវនាកាកំបាំងមុខ នោះសាលក្រមថ្មីនេះនូវចូលជាធរមាន"។

របស់ជនជាប់ចោទ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង R ទល់នឹង Wheland តុលាការកំពូលរបស់ប្រទេសអង់គ្លេស បញ្ជាក់ថា ការកែប្រែភាពគ្មានទោសរបស់ជនជាប់ចោទ ដែលត្រូវបានផ្តន្ទាទោសដោយមិនត្រឹមត្រូវ គឺជារឿងត្រឹមត្រូវដូចមានបញ្ជាក់ខាងក្រោមនេះ៖

> ប្រសិនបើ យើងយល់ឃើញថា ការផ្តន្ទាទោស ធ្វើឡើងដោយមិនត្រឹមត្រូវ និងខុសពីការពិត យើងត្រូវមានកាតព្វកិច្ចស្វែងរកការពិត និងយុត្តិធម៌ដល់ជននោះ។ មូលហេតុនៃមរណភាពរបស់ជនជាប់ចោទ ពុំមានផលប៉ះពាល់ដល់កាតព្វកិច្ចនេះទេ ដោយសារតែមរណភាពនេះគ្រាន់តែជាឧបសគ្គរាំងមិនឲ្យជនជាប់ចោទ អាចបន្តបណ្តឹងឧទ្ធរណ៍ដោយខ្លួនឯងផ្ទាល់។[50]

៥៣. ដូចគ្នានឹងករណីដែលបានលើកឡើងខាងលើផងដែរ នៅក្នុងសំណុំរឿង *State* ទល់នឹង *Webb* តុលាការកំពូលនៃប្រទេសកាណាដាបានបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីផលប្រយោជន៍យុត្តិធម៌ នីតិវិធីបណ្តឹងសាទុក្ខនៅតែបន្ត ក្រោយពេលជនជាប់ចោទបានទទួលមរណភាព នៅពេលដែលមូលដ្ឋាននៃបណ្តឹងសាទុក្ខមានមូលដ្ឋានគ្រប់គ្រាន់ និងលើសលប់ដោយមានភស្តុតាងបញ្ជាក់ពីភាពគ្មានទោសរបស់ដើមបណ្តឹងសាទុក្ខ។ ឱកាសក្នុងការស្តារកេរ្តិ៍ឈ្មោះនៃដើមបណ្តឹងសាទុក្ខ ដែលបានទទួលមរណភាពនោះ ត្រូវបានពិចារណាដោយតុលាការ ដោយហេតុថាពិតជាមានសារៈសំខាន់សម្រាប់គ្រួសារជននោះ។[51]

៥៤. ដូចគ្នាផងដែរ ក្នុងសំណុំរឿង *State* ទល់នឹង *Webb* តុលាការកំពូលរបស់សហរដ្ឋអាមេរិកនៅរដ្ឋវ៉ាស៊ីងតោន បានបញ្ជាក់ថាការកំណត់មិនឲ្យមានការបន្តនីតិវិធីបណ្តឹងសាទុក្ខ នាំឲ្យការផ្តន្ទាទោសមានភាពមិនត្រឹមត្រូវ និងមិនអនុញ្ញាតឲ្យទណ្ឌិតប្រើប្រាស់សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសលើរូបខ្លួន។ ការធ្វើបែបនេះជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ បើទោះបីជាជននោះស្លាប់បាត់បង់ជីវិតហើយក៏ដោយ។[52]

---

[50] សំណុំរឿង *R ទល់នឹង Wheland* ប្រទេសអង់គ្លេស និងប្រទេសវេល សាលាឧទ្ធរណ៍ (ផ្នែកព្រហ្មទណ្ឌ) [១៩៩៧] Crim. L.R. ៦៥៩ (**ឯកសារភ្ជាប់លេខ ៣៤**)។

[51] សំណុំរឿង *ប្រទេសកាណាដា R ទល់នឹង Smith* កថាខណ្ឌ៤៦-៤៧។

[52] សំណុំរឿង *សហរដ្ឋអាមេរិក ទល់នឹង Webb* កថាខណ្ឌ១៥-១៦។

៥៥. មូលហេតុផ្សេងទៀត ដែលគាំទ្រដល់ការបន្តនីតិវិធីបណ្តឹងសាទុក្ខដើម្បីផលប្រយោជន៍យុត្តិធម៌ បន្ទាប់ពីមរណភាពរបស់ដើមបណ្តឹងសាទុក្ខ រួមមាន ភាពចាំបាច់ដើម្បីដោះស្រាយបញ្ហាច្បាប់ដែលជាប្រយោជន៍សម្រាប់សាធារណជនទូទៅ ឬសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌។ បញ្ហាទាំងអស់នេះ គឺជាកង្វល់ដ៏ធំរបស់សាធារណជន ដែលកើតឡើងបន្ទាប់ពីការស្លាប់របស់ដើមបណ្តឹងសាទុក្ខ។[53]

៥៦. សរុបសេចក្តីមក ការបកស្រាយដោយសង្ខេបពីយុត្តាធិកាក្នុងស្រុកខាងលើ បង្ហាញថាដើម្បីផលប្រយោជន៍យុត្តិធម៌ ក្នុងទម្រង់ផ្សេងៗ ទាមទារឲ្យមានជម្រើសផ្សេងទៀត ក្រៅពីការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ ដើម្បីឲ្យនីតិវិធីបណ្តឹងសាទុក្ខនៅតែអាចបន្ត ក្រោយពីដើមបណ្តឹងសាទុក្ខបានទទួលមរណភាព ដោយផ្អែកលើមូលដ្ឋានពិសេសមួយ ដើម្បីឲ្យមានសមធម៌ដល់ភាគីទាំងអស់។

**ខ. វិធានពេញលេញក្នុងការបញ្ចប់នីតិវិធី ដែលអនុវត្តនៅក្នុងសំណុំរឿង *Delić* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ**

៥៧. ដូចដែលបានលើកឡើងខាងលើក្នុងផ្នែកទី III-គ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជាតុលាការព្រហ្មទណ្ឌអន្តរជាតិដំបូង ដែលបានដោះស្រាយលើករណី មរណភាពរបស់ដើមបណ្តឹងសាទុក្ខមុនពេលសាលដីកា ត្រូវបានប្រកាស។ នៅពេលនោះ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានចេញសេចក្តីសម្រេចបញ្ចប់នីតិវិធីដែលផ្ទុយពីជំហររបស់ព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី (ដែលភាគីទាំងពីរបានស្នើរសុំឲ្យបន្តនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង *Delić*) និងប្រកាសថាសាលក្រមលើជនជាប់ចោទ *Delić* គឺជាសាលក្រមស្ថាពរ។[54]

៥៨. ដូចដែលនឹងបញ្ជាក់នៅផ្នែកខាងក្រោម វិធានក្នុងការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខទាំងស្រុង បន្ទាប់ពីមរណភាពនៃដើមបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

---

[53] សូមពិនិត្យមើល ឧទាហរណ៍ សំណុំរឿង *ប្រទេសកាណាដា ទល់នឹង Smith* កថាខណ្ឌ៥០; ហុងកុង សំណុំរឿង*រដ្ឋាភិបាលតំបន់រដ្ឋបាលពិសេសហុងកុង ទល់នឹង Cheng Chee-Tock Theodore* កថាខណ្ឌ ៣២-៣៣។

[54] សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង *Delić* កថាខណ្ឌ១៦។

សម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងសំណុំរឿង *Delić* មានកំហុសផ្នែកច្បាប់ ហើយមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ។

## ១. ការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូល អំពីយុត្តាធិការបុគ្គល មានកំហុសឆ្គង

៥៩. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី យល់ឃើញថា ខ្លួនគ្មានជម្រើសអ្វីផ្សេងក្រៅតែពីកំណត់បញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ ពីព្រោះថាអង្គជំនុំជម្រះមិនមានយុត្តាធិការបុគ្គល លើដើមបណ្តឹងសាទុក្ខដែលទទួលមរណភាពនោះទេ។ [55] ទោះជាណាក៏ដោយអង្គជំនុំជម្រះតុលាការកំពូល មានកំហុសឆ្គងក្នុងការបកស្រាយច្បាប់ ។

៦០. អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា យុត្តាធិការបុគ្គលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺមានកំរិតអនុវត្តតែទៅលើជនដែលនៅរស់រានមានជីវិតប៉ុណ្ណោះ ដោយសារតែមាត្រា៦ នៃលក្ខន្តិកៈសាលាក្តីអន្តរជាតិនេះចែងថា យុត្តាធិការរបស់ខ្លួន អាចអនុវត្តតែទៅលើ“បុគ្គលមានជីវិត”។ ក៏ប៉ុន្តែក្នុងដំណើរការរៀបចំ (ដំណើរការរៀបចំដំបូង) បង្កើតលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបង្ហាញយ៉ាងច្បាស់ថា ពាក្យ“បុគ្គលមានជីវិត”[56] មិនត្រូវបានប្រើប្រាស់ក្នុងការកម្រិតយុត្តាធិការឲ្យអនុវត្តតែទៅលើបុគ្គលដែលនៅមានជីវិតនោះទេ ប៉ុន្តែមានការកម្រិតទៅលើ*នីតិបុគ្គល*មួយចំនួនដូចជា សមាគម ឬស្ថាប័នជាដើម។[57]

៦១. មិនត្រឹមតែការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អំពីអត្ថន័យនៃពាក្យ“បុគ្គលមានជីវិត” ក្នុងមាត្រា៦ នៃលក្ខន្តិកៈរបស់តុលាការខាងលើ មានកំហុសទាំងស្រុង ដោយយោងទៅលើការរៀបចំដំបូងប៉ុណ្ណោះទេ ប៉ុន្តែការបកស្រាយអំពីយុត្តាធិការបុគ្គលនេះ ថែមទាំងមានលក្ខណៈផ្ទុយពីការអនុវត្តទូទៅនៅក្នុងស្រុករហូតដល់យុត្តាធិការសំខាន់ៗ នៅជុំវិញពិភពលោកទៀតផង។

---

[55] សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង *Delić* កថាខណ្ឌ៨។

[56] សេចក្តីសម្រេចនៃនីតិវិធីក្នុងសំណុំរឿង *Delić* កថាខណ្ឌ៦។

[57] ៥៧. ឯកសារអង្គការសហប្រជាជាតិ S/25704 “របាយការណ៍លេខាធិការអង្គការសហប្រជាជាតិ យោងតាមកថាខណ្ឌ ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លេខ ៨០៨ (ឆ្នាំ១៩៩៣) ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៣” (**ឯកសារភ្ជាប់លេខ ៣៥**) កថាខណ្ឌ ៥០-៥២។

៦២. ឧទាហរណ៍ ការផ្អែកយ៉ាងសំខាន់លើការបកស្រាយពីយុត្តាធិការបុគ្គល អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសំណើរបស់មេធាវីការពារក្ដីរបស់ *Delić* ដែលស្នើរសុំឱ្យពិនិត្យសាលក្រមឡើងវិញ។[58] ទោះជាយ៉ាងណា នៅក្នុងយុត្តាធិការក្នុងស្រុកជាច្រើន សំណើសុំធ្វើការពិនិត្យសាលក្រមស្ដាពរឡើងវិញ គឺអាចធ្វើបានដោយស្របច្បាប់ ទោះបីជា ក្រោយពេលពិរុទ្ធជននោះទទួលមរណភាពហើយក៏ដោយ។ [59]

៦៣. ហេតុដូច្នេះ ការរក្សាជំហររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Delić* ថា ត្រូវតែបញ្ចប់ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ គឺជាការយោងទៅលើការបកស្រាយដែលមានកំហុសផ្នែកច្បាប់ទាំងស្រុង ហេតុនេះហើយ ពុំមានការផ្ដល់ជាគំរូត្រឹមត្រូវដល់អង្គជំនុំជម្រះក្នុងករណីនេះទេ។

## ២. វិធាននៃការបញ្ចប់បណ្ដឹងសាទុក្ខក្នុងសំណុំរឿង *Delić* មិនអាចអនុវត្តនៅ អ.វ.ត.ក បានឡើយ

៦៤. ក្រៅពីចំណុចត្រឹមត្រូវមួយចំនួននៅក្នុងសំណុំរឿង *Delić* ក្នុងកាលៈទេសៈណាក៏ដោយ មិនអាចយកមកអនុវត្តនៅក្នុង អ.វ.ត.ក បានឡើយ ដោយយោងលើហេតុផលមួយចំនួន។

៦៥. វិធានផ្ទៃក្នុង ១១២ (១) បានបញ្ជាក់យ៉ាងច្បាស់ថា សាច់ញាតិរបស់ទណ្ឌិត ឬជនដែលទទួលបានការបញ្ជាក់ជាលាយលក្ខអក្សរពីទណ្ឌិត អាចស្នើឱ្យអង្គជំនុំជម្រះ ពិនិត្យសាលក្រមស្ដាពរឡើងវិញ បន្ទាប់ពីមរណភាពរបស់ពិរុទ្ធជននោះ ។ វិធាននេះបង្ហាញថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មិនកម្រិតតែទៅលើបុគ្គលដែលនៅរស់រានមានជីវិតនោះទេ។ ដូច្នេះ វិធានក្នុងសំណុំរឿង *Delić* ដែលបញ្ចប់នីតិវិធីក្រោយការទទួលមរណភាពរបស់ដើមបណ្ដឹងសាទុក្ខ ដោយយោងទៅលើយុត្តា-ធិការបុគ្គលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានកំណត់តែ

---

[58] សំណុំរឿង *រដ្ឋអញ្ញា ទល់នឹង Delić* លេខ IT-04-83-R.1. "សេចក្ដីសម្រេចលើសំណើររបស់ក្រុមមេធាវីការពារក្ដី" ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៣ កថាខណ្ឌ ១។

[59] សូមពិនិត្យមើល ក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា មាត្រា៤៤៦ (**ឯកសារភ្ជាប់៣៦**); ប្រទេសបារាំង ក្រមព្រហ្មទណ្ឌ មាត្រា ៦៦២-២; ប្រទេសអាឡឺម៉ង់ ក្រមព្រហ្មទណ្ឌ មាត្រា៣៦១; Bosnia និង Herzegovina ក្រមព្រហ្មទណ្ឌ មាត្រា៣២៩; ប្រទេសអ៊ីតាលី ក្រមព្រហ្មទណ្ឌ មាត្រា៦៣២; Azerbaijan ក្រមព្រហ្មទណ្ឌ មាត្រា៤៦៤.៥; ប្រទេសរុស្ស៊ី ក្រមព្រហ្មទណ្ឌ មាត្រា២៤(១)(៤) និង ៥(៣៤); សាធារណរដ្ឋប្រជាមានិតចិន ក្រមព្រហ្មទណ្ឌ២០១៨ មាត្រា២៥២និង២៩៧(២); ប្រទេសអូស្ត្រាលី បទឧក្រិដ្ឋ (បណ្ដឹងឧទ្ធរណ៍ និងការត្រួតពិនិត្យ) Act ២០០១, SS77 និង៨៦ (**ឯកសារភ្ជាប់៣៧**)។

លើបុគ្គលនៅមានជីវិតនោះ ពុំអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ ទោះក្នុងករណីណាក៏ដោយ។

៦៦. ជាងនេះទៅទៀត ការលើកឡើងនៅក្នុងសំណុំរឿង *Delić* មិនបានផ្ដល់នូវគំរូត្រឹមត្រូវសម្រាប់ឲ្យ អ.វ.ត.ក អនុវត្តនោះទេ ដោយសារតែ ពួកគេទំនងជាធ្វើឡើងដោយផ្អែកទៅលើការពិចារណាពីហិរញ្ញវត្ថុ។ ផ្ទុយពីសំណុំរឿង *Delić* អ.វ.ត.ក បានបញ្ជាក់យ៉ាងច្បាស់ និងត្រឹមត្រូវថា សេចក្ដីសម្រេចពាក់ព័ន្ធនឹងអង្គច្បាប់ និងអង្គហេតុ មិនត្រូវ"ស្ថិតនៅក្រោមឥទ្ធិពលនៃហេតុផលហិរញ្ញវត្ថុនោះទេ"។ [60] ជាការពិត បន្ទាប់ពីមានការវិភាគយ៉ាងម៉ត់ចត់លើសេចក្ដីសម្រេចក្នុងសំណុំរឿង *Delić* សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីរបស់ អ.វ.ត.ក Michael Bohlander បានជំទាស់នឹងយុទ្ធសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងអត្ថបទសិក្សាស្រាវជ្រាវចុះផ្សាយនៅក្នុងឆ្នាំ២០១០ ដូចដែលមានបញ្ជាក់ដូចខាងក្រោមថា៖

> កំណត់ត្រាខ្លីនេះ នឹងបង្ហាញពីយុទ្ធសាស្ត្រដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងការដោះស្រាយបញ្ហានេះ និងសន្និដ្ឋានថា ពុំមែនជាលើកទីមួយទេ ដែលចៅក្រមពុំបានបកស្រាយឲ្យបានសមស្រប និងក្បោះក្បាយលើបញ្ហាច្បាប់ ដែលបង្កឲ្យមានបញ្ហាប្រឈមបន្ថែមលើបញ្ហាយុទ្ធសាស្ត្រនៃការបញ្ចប់នីតិវិធីជំនុំជម្រះ ខណៈដែលកេរ្តិ៍ដំណែលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មានឥទ្ធិពលធំធេងទៅលើការបញ្ចប់នីតិវិធីនៅក្នុងសាលាជម្រះក្ដី។[61]

៦៧. ដូចដែលអង្គជំនុំជម្រះបានដឹងច្បាស់រួចមកហើយ ក្នុងកំឡុងពេលចចារបង្កើត អ.វ.ត.ក អង្គការសហប្រជាជាតិទាមទារឲ្យមានតុលាការអន្តរជាតិ និងសង្កត់ធ្ងន់ឲ្យមាន "បទដ្ឋានអន្តរជាតិ" នៃ

---

[60] ឯកសារ **E284/4/8** "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងអំពីការបំបែកសំណុំរឿង០០២" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ("សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីការបំបែកសំណុំរឿង០០២ លើកទីពីរ") កថាខណ្ឌ ៧៥។

[61] Michael Bohlander *ការស្លាប់របស់ភាគីបណ្ដឹងសាទុក្ខ ការបញ្ចប់នីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង Rasim Delić នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ICTY*, ២១ Crim L. Forum ៤៩៥ (២០១០) កថាខណ្ឌ ៤៩៦ ("Bohlander, ការបញ្ចប់នីតិវិធីបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង *Delić*" **ឯកសារភ្ជាប់លេខ ៣៨**)។

ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (ដោយមិនលំអៀង និងគោរពតាមនីតិវិធីច្បាប់ ) តាមរយៈឯកសារច្បាប់របស់ អ.វ.ត.ក វិសោធនកម្មច្បាប់ អ.វ.ត.ក បានបញ្ជាក់លើចំណុចនេះយ៉ាងច្បាស់។ កិច្ចខិតខំប្រឹងប្រែងកន្លងមក នឹងក្លាយជាឥតប្រយោជន៍ ប្រសិនបើសវនាកានៅក្នុងសំណុំរឿង ០០២ នឹងត្រូវបរាជ័យ នៅដំណាក់កាលចុងក្រោយបំផុត ដោយសារតែការពិចារណាពុំសមហេតុផល ដូចជាមូលហេតុហិរញ្ញវត្ថុ និងការបញ្ចប់គម្រោង ជាដើម។

៦៨. សរុបសេចក្តីមក សេចក្តីសម្រេចក្នុងការបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង *Delić* គឺមិនសមស្របនឹងបទដ្ឋានអន្តរជាតិ និងពុំបានផ្តល់ជាគំរូត្រឹមត្រូវដល់ អ.វ.ត.ក ឡើយ។

**គ. ការលុបចោលនីតិវិធីក្រោយមរណភាពរបស់ដើមបណ្តឹងសាទុក្ខ ពុំមែនសុទ្ធតែជាការគិតពីផលប្រយោជន៍យុត្តិធម៌នោះទេ**

៦៩. ដូចបានបង្ហាញខាងលើក្នុងផ្នែកទី ៣ អនុលោមតាមវិធាននីតិវិធីដែលមានស្រាប់នៅ អ.វ.ត.ក ការបញ្ចប់កិច្ចដំណើរការនីតិវិធី និងបន្ទាប់មកលុបចោលអានុភាពអនុវត្តសាលក្រមសាលាដំបូង គឺជាជម្រើសបច្ចុប្បន្នតែមួយគត់ ដែលអង្គជំនុំជម្រះមាន នៅក្នុងករណីមរណភាពនៃដើមបណ្តឹងសា-ទុក្ខ។ ក៏ប៉ុន្តែ មានយុត្តាធិការក្នុងស្រុកជាច្រើន ដូចមានលើកឡើងក្នុងផ្នែកទី III-ខ និង IV-ក យល់ឃើញថា ការបញ្ចប់នីតិវិធី គឺពុំមែនសុទ្ធតែដើម្បីផលប្រយោជន៍យុត្តិធម៌នោះទេ ហើយជម្រើសដែលអនុញ្ញាតអោយមានការបន្តដំណើរការនីតិវិធី ក្នុងករណីលើកលែងមួយ គឺអាចជាជម្រើសបន្ថែម ឬជម្រើសជំនួសដ៏ចាំបាច់មួយ។ កាលៈទេសៈជុំវិញសំណើនេះធ្វើឡើងដើម្បីស្នើសុំអោយមានការធ្វើលើកឡើងនូវជម្រើសជំនួសមួយ ដើម្បីអនុញ្ញាតអោយមានការបន្តនីតិវិធីបណ្តឹងសាទុក្ខ ក្រោយពីមរណភាពរបស់លោក នួន ជា។

៧០. ប្រសិនបើ នីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ត្រូវបញ្ចប់ដោយអនុលោមតាមវិធានដែល អ.វ.ត.ក មានបច្ចុប្បន្ននេះ លទ្ធផលនេះនឹងចូលរួមចំណែកក្នុងការរំលោភបំពានដល់ផលប្រយោជន៍យុត្តិធម៌យ៉ាងធ្ងន់ធ្ងរ ។ ជាការពិតណាស់ ដោយហេតុថា ជនជាប់ចោទទាំងពីរ គឺជាអ្នកតំណាងចុងក្រោយបង្អស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចនេះ លទ្ធផលនៃសំណុំរឿងនេះ មានសារៈសំខាន់ក្រៃលែងសម្រាប់ប្រទេសកម្ពុជា ក៏ដូចទៅនឹងសហគមអន្តរជាតិ ដែលមានសិទ្ធិទទួលបាននូវសាលដីកាចុងក្រោយបង្អស់មួយ ដែលបញ្ជាក់អោយឃើញច្បាស់ពីព្រឹត្តិការណ៍ពិត។ សាលដីកា

ចុងក្រោយនេះផងដែរ ក៏មានសារៈសំខាន់ក្រៃលែងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលសិទ្ធិក្នុងការទទួលបានសំណង ដែលនឹងត្រូវបានបដិសេធចោល ប្រសិនបើ នីតិវិធីត្រូវបញ្ឈប់នៅដំណាក់កាលនេះ។ ជាចុងបញ្ចប់ ការបន្តបំពេញឲ្យចប់សព្វគ្រប់ ចំពោះនីតិវិធីបណ្ដឹងសាទុក្ខចំពោះសំណុំរឿង ០០២/០២នេះ មានសារៈសំខាន់ណាស់ចំពោះលោក នួន ជា ដោយសារតែនីតិវិធីបណ្ដឹងសាទុក្ខនេះ គឺជាឱកាសចុងក្រោយតែមួយគត់របស់គាត់ក្នុងការបង្ហាញពីការពិតទៅកាន់ប្រជាជនកម្ពុជា។ ផ្អែកលើវិធាននីតិវិធីដែលមានសព្វថ្ងៃនេះ រាល់ផលប្រយោជន៍ និងសារៈសំខាន់ទាំងនេះប្រាកដជាត្រូវបានបដិសេធ។

៧១. បន្ថែមលើផលប្រយោជន៍យុត្តិធម៌ ដែលសវនាការក្នុងស្រុកនៃរឿងក្ដីព្រហ្មទណ្ឌ ជាទូទៅអាចផ្ដល់ឲ្យសវនាការនៃរឿងក្ដីព្រហ្មទណ្ឌអន្តរជាតិមានចរិកលក្ខណៈពិសេសមួយ។ ក្រៅពីទិដ្ឋភាពច្បាប់ សវនាការប្រភេទនេះ តែងតែចូលរួមចំណែកក្នុងផ្នែក ប្រវត្តិសាស្ត្រ នយោបាយ និងសីលធម៌ផងដែរ ដែលជាទូទៅវាត្រូវបានប្រើប្រាស់ជាវិធីសាស្ត្រក្នុងការជួលគាំទ្រដល់ការសម្របសម្រួល នៅក្នុងសង្គម។ ហេតុដូចនេះ សវនាការនៃរឿងក្ដីព្រហ្មទណ្ឌអន្តរជាតិ តែងផ្ដល់លទ្ធផលប្រសើរ ចំពោះផលប្រយោជន៍សាធារណៈ ក្នុងការបង្ហាញពីការព្រឹត្តិការណ៍ពិត។ ដូចនេះ សវនាការប្រភេទនេះគួរតែទទួលបាននូវវិធានពិសេសដែលសក្ដិសមតាមគុណតម្លៃពិសេសរបស់ខ្លួន។

៧២. អង្គជំនុំជម្រះនេះ ធ្លាប់បានទទួលស្គាល់រួចមកហើយនូវចរិកលក្ខណៈជាក់លាក់នៃសវនាការក្រោមយុត្តាធិការរបស់ខ្លួន និងភាពចាំបាច់ផ្សេងៗក្នុងការធានាបាននូវការបញ្ចប់កិច្ចដំណើរការនីតិវិធី ដើម្បីផលប្រយោជន៍យុត្តិធម៌៖

*មានការពាក់ព័ន្ធផលប្រយោជន៍សាធារណៈយ៉ាងខ្លាំង ("ការបិទសិទ្ធិ និងការជះឥទ្ធិពលលើផលប្រយោជន៍ផ្នែកច្បាប់") ក្នុងការចោទប្រកាន់ជនជាប់ចោទ។ វត្តមានរបស់តុលាការនេះនិងការតស៊ូរបស់ខ្លួនតាមរយៈដំណើរការនៃការចរចារមតិ និងប្រតិបត្តិការបន្តបន្ទាប់ ក្នុងរូបភាពជាស្ថាប័ន គឺជាសក្ខីភាពមួយដែលបង្ហាញពីការគិតពីផលប្រយោជន៍សាធារណៈជន ដើម្បីកាត់ទោសឧក្រិដ្ឋជននិងឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ខ្លួន និងដើម្បីបង្កានិទណ្ឌភាព និងជំរុញការផ្សះផ្សាជាតិ។ ជាការពិតណាស់ ការកាត់ទោសជនជាប់ចោទ គឺពិតជាដើម្បីបម្រើផលប្រយោជន៍សាធារណៈដោយគ្មានអ្វីអាចប្រកែកបាននោះទេ ហើយវាក៏បានបង្ហាញតាមរយៈដំណាក់កាលនីតិវិធីមុនសវនាការ នាពេលដែលអង្គបុរេជំនុំជម្រះបានចេញលទ្ធផលសម្រេចចោទប្រកាន់ជន*

*ជាប់ចោទ។ លើសពីនេះទៀត ដោយហេតុថាជនជាប់ចោទមិនបានសារភាពទទួលពិរុទ្ធភាពឡើយ ដូចនេះយ៉ាងហោចណាស់ច្បាប់បានផ្តល់ប្រយោជន៍ទៅអោយភាគីនៃក្រុមការពារក្តីក្នុងការប្តឹងសាទុក្ខប្រឆាំងនីតិវិធីដោយផ្អែកលើគោលការណ៍សច្ចធារណ៍នៃនិរទោស។ ចំណុចនេះក៏មានផលប្រយោជន៍សម្រាប់ជនរងគ្រោះក្នុងការទទួលបានការបញ្ជាក់នូវការពិត និងទាមទារសំណងសម្រាប់ពួកគេ។*[62]

៧៣. សំណុំរឿង ០០២/០២ គ្របដណ្តប់ការចោទប្រកាន់ចំនួន ២២ករណី រួមមាន គោលនយោបាយទូទាំងប្រទេសចំនួនប្រាំ ទីតាំងបទល្មើសចំនួនប្រាំបី និងព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់រាប់មិនអស់ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សំណុំរឿង ០០២/០២ ក៏បានតំណាងឲ្យនីតិវិធីដែលបានធ្វើឡើងក្នុងរយៈពេលជិតប្រាំឆ្នាំ ដែលក្នុងនោះ រួមបញ្ចូលរយៈពេល២ឆ្នាំកន្លះនៃសវនាការ ហើយមានសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៧២នាក់ត្រូវបានស្តាប់ចម្លើយ និងឯកសារចំនួន ១១.០០០ ត្រូវបានទទួលស្គាល់ជាភស្តុតាង។ ការបញ្ចប់នីតិវិធីនេះ ដោយមានឥទ្ធិពលរារាំងអានុភាពអនុវត្តសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅដំណាក់កាលនេះ ខណៈពេលដែលដើមបណ្តឹងសាទុក្ខបានជូនដំណឹងលម្អិតពីការប្តឹងសាទុក្ខរបស់ខ្លួន នឹងបណ្តាលអោយមានការខ្ជះខ្ជាយនូវធនធាន និងការខិតខំប្រឹងប្រែង ដ៏គួរអោយសោកស្តាយមួយ។

៧៤. ការអនុញ្ញាតិឲ្យមានករណីលែកលែង ដើម្បីបន្តនីតិវិធីពាក់ព័ន្ធនឹងលោក នួន ជា ក្រោយមរណភាពរបស់គាត់ គឺជាមធ្យោបាយតែមួយគត់ ដើម្បីបម្រើដល់ផលប្រយោជន៍រួមក្នុងការស្វែងរកយុត្តិធម៌ ហើយវានឹងអាស្រ័យទាំងស្រុងលើអង្គជំនុំជម្រះក្នុងការសម្រេចចិត្តក្នុងការបន្ថែមជម្រើសនេះ ចូលទៅក្នុងវិធានបច្ចុប្បន្នរបស់ អ.វ.ត.ក មានដូចជាវាធ្លាប់យកមកពិចារណាដោយយុត្តាធិការក្នុងស្រុកជាច្រើនជុំវិញពិភពលោក។

**ឃ. ជម្រើសបន្ថែមដើម្បីអោយមានការបន្តនីតិវិធីប្តឹងសាទុក្ខនេះ ពុំមានភាពផ្ទុយជាមួយនឹងវិធាន អ.វ.ត.ក បច្ចុប្បន្នទាំងនេះទេ**

៧៥. ដូចបានកំណត់ខាងលើ ខណៈពេលដែលវិធានបច្ចុប្បន្នដែលត្រូវបានកំពុងអនុវត្តក្នុងអ.វ.ត.ក តម្រូវអោយបញ្ចប់រាល់នីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកស្លាប់ វិធានទាំងនោះពុំបានហាមមិនអោយបន្ត

---

[62] E138/1/10/1/5/7, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥទលក្ខខណ្ឌ, កថាខណ្ឌ ២៨

នីតិវិធីពាក់ព័ន្ធទៅនឹងបុគ្គលទទួលមរណភាពនោះទេ។[63] លើសពីនេះទៅទៀត ទាំងវិធានផ្ទៃក្នុង[64] និងច្បាប់ប្រទេសកម្ពុជា[65] បានផ្តល់ការគាំពារជាក់លាក់ក្នុងការទប់ស្កាត់អង្គជំនុំជម្រះពីការបន្ថែមស្ថានទំងន់ទៅលើសាលក្រម ឬបន្ថែមលើទំហំនៃសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលជនសង្ស័យជាដើមបណ្តឹងសាទុក្ខ។ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះអាចត្រឹមធ្វើការកែប្រែសាលក្រម ក្នុងអត្ថន័យមួយដែលនឹងអាចផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទតែប៉ុណ្ណោះ។

៧៦. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ លោក នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងសាទុក្ខរបស់លោក ផ្អែកលើមូលដ្ឋានសាទុក្ខចំនួន៥៤៣ ដើម្បីទាមទារអោយមានការច្រានចោលសាលក្រមមុនទាំងស្រុង[66]។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញា បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងសាទុក្ខដោយផ្អែកលើមូលដ្ឋានតែមួយគត់គឺ៖

*អង្គជំនុំជម្រះ បានសម្រេចខុសពីច្បាប់ និងការពិត ដោយយល់ឃើញថាជនរងគ្រោះប្រុសនៃការបង្ខំអោយរៀបការ ដែលត្រូវបានបង្ខិតបង្ខំអោយរួមភេទដោយពុំមានការស្មគ្រចិត្ត គឺមិនមែនជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រង់ចំណុច សកម្មភាពអមនុស្សធម៌ផ្សេងៗ នោះទេ។*[67]

៧៧. ការប្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផ្តោតទៅលើតែបញ្ហានៃការបកស្រាយច្បាប់ ដែលការប្តឹងនេះនឹងពុំនាំអោយមានការច្រានចោលនូវសាលក្រម ឬផ្នែកណាមួយនៃសាលក្រមនោះទេ។ ក្នុងរូបភាពនេះ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជាការប្តឹងដែលពុំមានគុណតំលៃឡើយ ខុសប្លែកពីការប្តឹងសាទុក្ខធ្វើឡើងដោយជនជាប់ចោទ។ ដូច្នេះ ដោយផ្អែកទៅលើវិធានដែលអាចអនុវត្តបាន អង្គជំនុំជម្រះនៃសវនាការកំពូលពុំអាចបន្ថែមទម្ងន់ទោសដល់សាលដីកាបាននោះទេ ហើយវាមានន័យថា នីតិវិធីសាទុក្ខបច្ចុប្បន្ន អាចនាំអោយមានសេចក្តីសម្រេចមួយដែលផ្តល់ផលប្រយោជន៍ដល់ លោក នួន

---

[63] ចំពោះប្រធានបទនេះ ចៅក្រម Bohlander ក៏បានពិភាក្សាអំពីភាពខុសប្លែកគ្នារវាងនីតិវិធី**ប្រឆាំង**នឹងបុគ្គលម្នាក់ និង នីតិវិធី**ពាក់ព័ន្ធ**នឹងបុគ្គលម្នាក់។ មើល Bohlander, ការបញ្ចប់នីតិវិធីបណ្តឹងឧទ្ធរណ៍ នៅក្នុង *Delic*, ទំព័រ ៥០០។

[64] វិធានផ្ទៃក្នុង មាត្រា ១១០ (៣)។

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣៩៩។

[66] E465/3/1 "សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២", ០១ កក្កដា ២០១៩។ លេខនេះរួមបញ្ចូលទាំងអំនះអំនាងបន្ទាប់បន្សំ

[67] E465/2/1 "សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២", ២១ មិថុនា ២០១៩។

ជា។ ហេតុដូចនេះ នីតិវិធីដើរបន្តទៅមុខ ចំពោះមុខអង្គជំនុំជម្រះពុំអាចត្រូវបានចាត់ទុកថាជាការប្រឆាំងលោក នួន ជា នោះទេ។ ហើយវាក៏មានន័យថា វិធានទាំងឡាយដែលទប់ស្កាត់ការបន្តនីតិវិធីក្រោយដើមបណ្ដឹងសាទុក្ខទទួលមរណភាព មុនពេលទទួលបានសាលដីកាចុងក្រោយនោះ ពុំអាចយកមកអនុវត្តបានឡើយចំពោះស្ថានភាពបច្ចុប្បន្ននេះទេ។

៧៨. លើសពីនេះទៀត គំនិតនៃការផ្ដល់លទ្ធភាពអោយទាយាទបន្តនីតិវិធី គឺពុំមានជារឿងថ្មែថ្មីឡើយចំពោះ អ.វ.ត.ក។ ដូចបានលើកឡើងខាងលើ[68] វិធានផ្ទៃក្នុងទទួលយកការពិចារណាចំពោះកាលៈ-ទេសៈជាក់លាក់ ក្នុងការផ្ដល់លទ្ធភាពឲ្យជនដែលជនជាប់ចោទបានចាត់តាំងមុនពេលជនជាប់ចោទទទួលមរណភាព អាចបន្តនីតិវិធីក្នុងនាមជនជាប់ចោទបាន បន្ទាប់ពីជនជាប់ចោទទទួលមរណភាព។[69] លោក នួន ជា បានអនុវត្តសិទ្ធិនេះមុនពេលលោកទទួលមរណភាព និងបានផ្ដល់ជូនអង្គជំនុំជម្រះនូវលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរមួយ ចាត់តាំងដល់មេធាវីការពារក្ដី និងសមាជិកគ្រួសារមួយចំនួនរបស់គាត់អោយបន្តនីតិវិធីក្នុងមានរូបគាត់។

៧៩. សរុបមកវិញ វិធាននីតិវិធីបច្ចុប្បន្នដែលអាចអនុវត្តចំពោះ អ.វ.ត.ក ពុំបានហាមឃាត់នូវការបន្តនីតិវិធីពាក់ព័ន្ធលោក នួន ជា ក្រោយមរណភាពរបស់គាត់នោះឡើយ ហើយថែមទាំងបានគ្រោងទុកនូវគោលគំនិតស្ដីពីទាយាទ និងជនត្រូវបានចាត់តាំង ដើម្បីបន្តនីតិវិធីក្នុងនាមរូបគាត់ រួចទុកជាមុនថែមទៀតផង។ ផ្អែកលើអ្វីដែលបានលើកឡើងខាងលើ ការបើកជម្រើសអោយមានការបន្តនីតិវិធីនៅក្រោមកាលៈទេសៈជាក់លាក់ ដែលអាចដឹងប្រាកដថាលទ្ធផលនៃដំណើរការនីតិវិធីអាចផ្ដល់ផលប្រយោជន៍តែទៅកាន់លោក នួន ជា នឹងមិននាំឱ្យមានការផ្ទុយណាមួយជាមួយនឹងវិធាននៃនីតិវិធីបច្ចុប្បន្នដែលមានស្រាប់នោះទេ។

**ខ. អង្គជំនុំជម្រះ មានអំណាចក្នុងការបង្កើតវិធាននីតិវិធី ហើយកិច្ចប្រជុំពេញអង្គ មានអំណាចក្នុងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុង**

៨០. កន្លងមក អង្គជំនុំជម្រះនេះធ្លាប់បានទទួលស្គាល់ថា មាត្រា១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ផ្ដល់អំណាចអោយ អង្គជំនុំជម្រះធ្វើការ "បង្កើតថ្មី" ចំពោះមាតិកា ឬវិធានទាំងឡាយណាក្រោមវិសាល

[68] *មើលផ្នែកទី២ ជំពូក IV*

[69] វិធានផ្ទៃក្នុង មាត្រា ១១២ (១)

ភាពវិធាននីតិវិធីរបស់អ.វ.ត.ក។ [70] ជាឧទាហរណ៍ គោលជំហរនេះក៏បានឆ្លុះបញ្ចាំងដោយប្រយោលពីគោលជំហរលើកមុនរបស់អង្គជំនុំជម្រះ បើទោះបីជា វិធាននីតិវិធីរបស់អ.វ.ត.ក មានភាពស្ងៀមស្ងាត់លើលទ្ធភាពនៃការដកចេញ ឬបញ្ចប់ការចោទប្រកាន់ តាមប្រព័ន្ធតុលាការប្រឆាំងនឹងជនជាប់ចោទ ក៏ការអនុវត្តបិទសំណុំរឿងមុនពេលកំណត់នេះ ពុំមែនសុទ្ធតែមានភាពចាំបាច់នោះទេ។[71]

៨១. ដំណោះស្រាយចំនួន២ សម្រាប់កំណែនីតិវិធីតុលាការថ្មីនៅ អ.វ.ត.ក ត្រូវបានផ្ដល់អោយដោយប្រយោលក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក:

(ក) ការបកស្រាយវិធាននីតិវិធី "នៅពេលដែលមានភាពមិនច្បាស់លាស់ពាក់ព័ន្ធទៅនឹងការបកស្រាយ ឬការអនុវត្តនៃវិធានដែលពាក់ព័ន្ធនឹងច្បាប់ប្រទេសកម្ពុជា"។ និង

(ខ) ការអភិវឌ្ឍវិធាននីតិវិធី នៅពេលដែល:

(i) "ច្បាប់ប្រទេសកម្ពុជាមិនដោះស្រាយជាមួយបញ្ហាជាក់លាក់ណាមួយ" ឬ

(ii)"មានចំណោទសំនួរពាក់ព័ន្ធនឹងភាពស៊ីចង្វាក់គ្នារវាងវិធាន (ដែលមានស្រាប់) ជាមួយនឹងបទដ្ឋានអន្តរជាតិ"។[72]

៨២. អំណាចនៃប្រព័ន្ធតុលាការទាំងនេះ មានភាពស៊ីចង្វាក់គ្នានឹងអង្គហេតុដែល អ.វ.ត.ក ធ្លាប់មានពីមុនមកដែរ ដូចដែលអង្គបុរេជំនុំជម្រះធ្លាប់បានលើកឡើងអំពីវាថា "វាគឺជារបបនៃការបង្កើតនូវច្បាប់នីតិវិធីដោយខ្លួនឯងផ្ទាល់ ដោយមូលហេតុនៃកាលៈទេសៈពិសេសរបស់វាដែលខុសប្លែកពីករណីដទៃ [....] ខុសប្លែកគួរអោយកត់សម្គាល់បើប្រៀបធៀបនឹងប្រតិបត្តិការទូទៅនៃតុលាការ

---

[70] E138/1/10/1/5/7, សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥទលក្ខខណ្ឌ, កថាខណ្ឌ ៣៣

[71] មើល E284/4/8, សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទី២របស់អង្គជំនុំជម្រះអង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, កថាខណ្ឌ ៦១-៦២ ផងដែរមើល E301/9/1, "សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២", ០៤ មេសា ២០១៤

[72] មើល សំអាងហេតុរបស់អង្គជំនុំជម្រះនៃសាលាដំបូង, E138/1/10/5/7, សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥទលក្ខខណ្ឌ, កថាខណ្ឌ ៣៣

ព្រហ្មទណ្ឌនៃប្រទេសកម្ពុជា និងដើម្បីធានាអោយបាននូវប្រព័ន្ធជាក់លាក់ត្រឹមត្រូវមួយ"។[73] វាអាចនិយាយម្យ៉ាងទៀតបានថា របបច្បាប់នៃ អ.វ.ត.ក អាចងាយនឹងមានភាពមិនស៊ីចង្វាក់គ្នា ឬចន្លោះប្រហោង ដោយមូលហេតុថា របបច្បាប់នេះត្រូវត្រៀម ជាស្រេចក្នុងការបកស្រាយ (ឬបកស្រាយសារជាថ្មី) ឬវិវឌ្ឍបន្ថែមដើម្បីធានាអោយបាននូវដំណើការតួនាទីរបស់វា។

៨៣. បន្ថែមពីនេះទៅទៀត ឬអាចជាជម្រើសមួយផ្សេងទៀត នៅពេលដែលកាលៈទេសៈជាក់មួយដែលច្បាប់នៃប្រទេសកម្ពុជាមានភាពស្ងៀមស្ងាត់ទៅលើបញ្ហាណាមួយ មាត្រា២ និងមាត្រា៣(២) នៃវិធានផ្ទៃក្នុង ត្រូវបានធ្វើវិសោធនកម្មយ៉ាងជាក់លាក់ថា "សំណើដើម្បីធ្វើវិសោធនកម្ម (វិធានផ្ទៃក្នុង) ទាំងនេះ ត្រូវដាក់ទៅអោយគណៈកម្មាធិកានៃវិធាននីតិវិធី អោយបានឆាប់តាមដែលអាចធ្វើបាន"[74] ហើយបន្ទាប់មក "ការប្រជុំពេញអង្គដើម្បីធ្វើការអនុម័ត"។ ដូចបានបង្ហាញនេះ អង្គជំនុំជម្រះបានទម្លាក់ចោលការចោទប្រកាន់ដែលនៅសេសសល់ប្រឆាំងនឹងលោក នួន ជា និងលោក ខៀវ សំផន បន្ទាប់ពីវិធានផ្ទៃក្នុងត្រូវបានវិសោធនកម្ម ដើម្បីផ្តល់លទ្ធភាពអោយមានការទម្លាក់ចោលការចោទប្រកាន់ តាមរយៈ ផ្នែកមួយ នៃវិធានលេខ ៨៩។[75] ការធ្វើវិសោធនកម្មនេះ (ក្នុងខែមករា ឆ្នាំ២០១៥) បានកើតឡើង៦ខែក្រោយពេល ដែលអង្គជំនុំជម្រះនេះបានចេញដីកាបង្គាប់បញ្ឈប់នីតិវិធីជាបណ្តោះអាសន្ន ទាក់ទងនឹងការចោទប្រកាន់ក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង០០២/០២ ហើយក្រោយមកបានបង្គាប់អោយអង្គជំនុំជម្រះដំបូងបោះបង់ចោលការចោទប្រកាន់ដែលសេសសល់ទាំងនោះ។ ការធ្វើបែបនេះ អង្គជំនុំជម្រះនេះ បានស្តីបន្ទោសដល់សេចក្តីសម្រេច ដែលពុំមានភាពគត់មត់ច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការចោទប្រកាន់ដែលនៅសេសសល់ ហើយបានចង្អុលបង្ហាញថា ស្ថានភាពនេះអាចត្រូវបានដោះស្រាយតាមរយៈ ៖

[73] D55/1/8,សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីបង្គាប់បដិសេធសំណើសុំមោឃភាព

[74] ការសង្កត់បង្ហាញត្រូវបានបន្ថែម

[75] E439/5 "សេចក្តីសម្រេចបង្រួមវិសាលភាពនៃសំណុំរឿង០០២/០២", ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧។

*ការប្រើប្រាស់អំណាចនៃមាត្រា១២ នៃកិច្ចព្រមព្រៀងអ.វ.ត.ក ឬតាមរយៈការកោះប្រជុំពេញអង្គលើប្រធានបទសំណើរបស់សហព្រះរាជអាជ្ញាក្នុងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងដែលនឹងផ្តល់លទ្ធភាពឱ្យមានការដកចោល ឬកាត់បន្ថយការចោទប្រកាន់នៅក្នុងអ.វ.ត.ក។*[76]

៨៤. ខណៈពេលដែលក្រុមមេធាវីការពារក្តី ពុំមានឋានៈក្នុងការដាក់សំណើសុំអោយមានការធ្វើវិសោធនកម្មនេះ វិធានផ្ទៃក្នុងមាត្រា ៣(១) បានផ្តល់អំណាចឱ្យអង្គចៅក្រមនៃ អ.វ.ត.ក អាចធ្វើសកម្មភាពនេះ ក្នុងចំណោមភាគីដែលទទួលបានសិទ្ធិប្រភេទនេះ។

## V. សេចក្តីសម្រេចនេះត្រូវធ្វើឡើងជាបន្ទាន់ ហើយក្រុមមេធាវីការពារក្តី នួន ជា ត្រូវបានរក្សាទុកយ៉ាងហោចណាស់រហូតដល់ពេលកំណត់មួយ

៨៥. វាហាក់ដូចជាបង្ហាញថា អង្គជំនុំជម្រះនៃតុលាការកំពូលកំពុងតែប្រឈមនឹងបញ្ហាធនធានធ្ងន់ធ្ងរ ទោះបីជាមានការទទួលបានសាលក្រមនៃសំណុំរឿង ០០២/០២ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ និងកំពុងស្ថិតនៅក្រោមការជូនដំណឹងអំពីការចេញសាលក្រម ចាប់តាំងពីពេលប្រកាសសាលក្រមដោយសង្ខេបនៅថ្ងៃទី១៦ ខែវិច្ឆិកាឆ្នាំ ២០១៨ ក៏ដោយ ។ ជាឧទាហរណ៍ ក្រុមមេធាវីការពារក្តីបានសិក្សាដឹងថាចៅក្រមអន្តរជាតិពីររូបកំពុងនឹងលាឈប់ពីតំណែងរបស់ខ្លួន ហើយវាមានភាពស៊ីចង្វាក់ជាមួយនឹងការតែងតាំងលោកស្រី Maureen Harding Clark ដែលត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩។ ផងដែរ វាមានការលេចឡើងក្នុងរូបភាពដែលអង្គជំនុំជម្រះកំពុងជួបបញ្ហាកង្វះបុគ្គលិក ហើយថ្មីៗនេះមានការផ្សព្វផ្សាយជ្រើសរើសមុខតំណែងជាច្រើននៅក្នុងអង្គជំនុំជម្រះ ដែលដំណើរការនៃការជ្រើសរើសបុគ្គលិកអាចនឹងចំណាយពេលវេលាយូរ។ ទោះយ៉ាងណាក៏ដោយ បញ្ហានៃធនធានពុំមែនជាកត្តាជះឥទ្ធិពលទៅលើការបន្តនីតិវិធី ឬ

---

[76] E301/9/1/1/3 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២/០២ និងវិសាលភាពនៃសំណុំរឿង០០២/០២", ២៩ កក្កដា ២០១៤, កថាខណ្ឌ ៨៨ និង ៩០។

ល្បឿនរបស់នីតិវិធីឡើយ ដូចដែលអង្គជំនុំជម្រះផ្ទាល់ធ្លាប់បានសង្កត់ធ្ងន់លើការពិចារណាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ។[77]

៨៦. អង្គជំនុំជម្រះនេះនិងអង្គជំនុំជម្រះដទៃ ជាពិសេសអង្គជំនុំជម្រះសាលាដំបូង ជាញឹកញាប់បានចេញសេចក្តីសម្រេចបដិសេធជាបន្ទាន់ នៅពេលកាលៈទេសៈតម្រូវឱ្យមាន។ ឧទាហរណ៍អង្គជំនុំជម្រះនេះ បានចេញសេចក្តីសម្រេចច្រានចោលលើសំណើសុំដាក់ភ័ស្តុតាងបន្ថែមក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ (បីសប្តាហ៍មុនពេលសវនាការនៃបណ្តឹងសាទុក្ខ ត្រូវដំណើរការ)។ អង្គជំនុំជម្រះចេញសេចក្តីសម្រេចបែបនេះដោយផ្អែកលើមូលដ្ឋានមួយផ្នែកដែលថា៖

> វាគឺដើម្បីផលប្រយោជន៍យុត្តិធម៌ក្នុងការច្រានចោលនូវសំណើសុំដាក់ភ័ស្តុតាងបន្ថែម នៅមុនកាលវិភាគសវនាការដែលបានគ្រោងទុក ហេតុដូចនេះភាគីមានលទ្ធភាពរៀបចំសេចក្តីថ្លែងការណ៍របស់ពួកគេ ដោយក្តោបបានរូបភាពពេញលេញនិងច្បាស់លាស់ផ្អែកលើមូលដ្ឋានភ័ស្តុតាង ដែលអង្គជំនុំជម្រះ នឹងយកធ្វើជាមូលដ្ឋានក្នុងការធ្វើការសម្រេចចំពោះការប្តឹងសាទុក្ខ[78]

៨៧. លោក នួន ជា បានទទួលមរណភាពនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។ កាលៈទេសៈជុំវិញការស្នើសុំនេះ គូសបញ្ជាក់ថា វាគឺដើម្បីផលប្រយោជន៍យុត្តិធម៌ ហើយយ៉ាងហោចណាស់ អង្គជំនុំជម្រះត្រូវផ្តល់សេចក្តីសម្រេចច្រានចោលមួយ ដោយផ្អែកលើភាពបន្ទាន់ចាំបាច់របស់ករណីនេះ។ ដូចគ្នានេះដែរ ដើម្បីផលប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះគប្បីចេញសេចក្តីបង្គាប់ផ្ទៃក្នុងមួយ មុនពេលដែលសេចក្តីសម្រេចណាមួយបានធ្វើឡើង ដើម្បីរក្សាទុកក្រុមមេធាវីការពារក្តី យ៉ាងហោចណាស់រហូតដល់ពេលវេលាសមរម្យមួយ ក្រោយពេលសេចក្តីសម្រេចដែលប្រកបដោយហេតុផលសមរម្យត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងសំណើនេះ។ មួយវិញទៀត ការចេញសេចក្តីបង្គាប់ផ្ទៃក្នុងបែបនេះ អាចអនុញ្ញាតអោយក្រុមមេធាវីការពារក្តីបន្តធ្វើការងារលើសារណាបណ្តឹងសាទុក្ខ ពីព្រោះថាលទ្ធផលមួយចំពោះសំណើនេះ អាចជាការទទួលយកសំណើបន្តនីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធ លោក នួន ជា ក្រោយមរណភាពរបស់គាត់។ មួយវិញទៀត ការរក្សាទុកក្រុមមេធាវីការពារក្តី លោក នួន ជា

---

[77] E284/4/8, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទី២របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, កថាខណ្ឌ ៧៥។

[78] F2/9, "សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ -ផ្នែកសេចក្តីសម្រេច-", ២១ តុលា ២០១៥, កថាខណ្ឌ ៦។

រហូតដល់ពេលវេលាសមរម្យមួយ ក្រោយពេលចេញនូវសេចក្តីសម្រេចដែលសមហេតុផលពេញលេញមួយចំពោះសំណើនេះ គឺជាការធានាផ្តល់នូវឱកាសដល់ភាគីទាំងអស់ក្នុងការដាក់សំណើ ដើម្បីអោយមានការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចនេះ ឬការឆ្លើយតបទៅនឹងសំណើនេះ។

៨៨. លើសពីនេះទៀត ការរក្សាទុកក្រុមមេធាវីការពារក្តីរបស់លោក នួន ជា គឺជាយុត្តិសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុតនៅក្នុងកាលៈទេសៈដែលពេលវេលាគឺជាកត្តាដ៏មានសារៈសំខាន់បំផុត។ ពេលវេលា និងការផ្តោតការយកចិត្តទុកដាក់ ដ៏សំខាន់ជាច្រើន នឹងត្រូវខាតបង់ ប្រសិនបើ ក្រុមមេធាវីការពារក្តីត្រូវបានបញ្ឈប់ ប្រតិបត្តិការនៃការចាកចេញពីការងារ រួចហើយត្រូវបានចាត់តាំងសារជាថ្មី និងឆ្លងកាត់ប្រតិបត្តិការក្នុងការចូលបម្រើការងារវិញ ជាពិសេសនៅពេលដែលសមាជិកនៃក្រុមការងារមានទីតាំងបំរើការងារនៅបរទេសត្រូវធ្វើការហោះចេញ និងចូល ដើម្បីបង្ហាញមុខក្នុងការបំពេញជំហ៊ាននីតិវិធីទាំងនេះ។

## IV. **សំណូមពរ**

៨៩. ផ្អែកតាមហេតុផលទាំងអស់ខាងលើ ក្រុមមេធាវីការពារក្តីស្នើសុំ ៖

(ក) ស្នើសុំអង្គជំនុំជម្រះ

(i) ទទួលយកសំណើរនេះថាដាក់បញ្ជូលបានត្រឹមត្រូវនិងបានការ ដោយហេតុថា ក្រុមមេធាវីការពារក្តីបានទទួលលិខិតអនុញ្ញាតិជាលាយលក្ខអក្សរពីលោក នួន ជា ដើម្បីធ្វើបន្តនីតិវិធីក្នុងនាមរូបគាត់ ឬ បើមិនដូច្នេះទេ សូមអោយ៖

(ii) សម្រេចចិត្តលើប្រធានបទនៃសំណើរនេះដោយឆន្ទានុសិទ្ធិ ផ្អែកលើការគិតពីផលប្រយោជន៍យុត្តិធម៍។

(ខ) ស្នើសុំអង្គជំនុំជម្រះសម្រេចថា៖

(i) បញ្ចប់នីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងលោក នួន ជា ដែលនាំអោយសាលក្រមក្នុងសំណុំរឿង ០០២/០២ ចំពោះលោក នួន ជា ត្រូវអស់អានុភាពអនុវត្តទាំងស្រុង ដោយ នួន ជា នៅតែទទួលបានសិទ្ធិសន្មត់ជាមុនថាគ្មានទោសក្រោយពេលបានប្តឹងសាទុក្ខ ឬ

(ii) ឬបើមិនដូច្នេះទេ អនុញ្ញាតឱ្យនីតិវិធីបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងលោក នួន ជា បន្ដដំណើរការទៅមុខដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ ដោយធានាឱ្យលោក នួន ជា ទទួលបានការការពារដោយក្រុមមេធាវីការពារក្ដីតាមឆន្ទៈរបស់គាត់ ក្រោយពីរូបលោកទទួលមរណភាព។

(គ) ប្រសិនបើមានភាពចាំបាច់ សូមអោយចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ស្នើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក តាមរយៈការប្រជុំពេញអង្គរបស់ អ.វ.ត.ក ដើម្បីបង្ហាញអោយឃើញច្បាស់ពីវិធានដែលអាចអនុវត្តបាន ពាក់ព័ន្ធនឹងប្រធានបទដែលត្រូវបានលើកឡើងក្នុងសំណើនេះ។

(ឃ) ស្នើសុំអង្គជំនុំជម្រះ៖

(i) ផ្ដល់នូវសេចក្ដីសម្រេចនេះ ឬសេចក្ដីសម្រេចច្រានចោលក្នុងកម្រិតអប្បបរមាដោយមានសេចក្ដីសម្រេចដ៏សមហេតុផលមួយ ដើម្បីឱ្យមានការអនុវត្តឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដោយឈរលើមូលដ្ឋាននៃភាពបន្ទាន់ និង

(ii) ចេញសេចក្ដីបង្គាប់បណ្ដោះអាសន្ន មុនពេលផ្ដល់នូវសេចក្ដីសម្រេចណាមួយ ដោយផ្ដល់នូវការរក្សាទុកក្រុមមេធាវីការពារក្ដី រហូតដល់ពេលណាមួយសមស្រប ដែលកំណត់ដោយអង្គជំនុំជម្រះ បន្ទាប់ពីមានការចេញសេចក្ដីសម្រេចនេះ។

សហមេធាវីការពារក្ដីលោក នួន ជា

សុន អរុណ　　　　លីវ សុវណ្ណា　　　　Doreen CHEN